# ស្ត្រីគ្រប់លក្ខណ៍ក្នុងអក្សរសិល្ប៍ខ្មែរ

ដោយបណ្ឌិតសភាចារ្យ ឃីង ហុកឌី

***ស្រី*** *ជាពាក្យ ដែលប្រជាជនខ្មែរយើងយកមកប្រើជាសាធារណៈ សម្គាល់មនុស្សជាតិដែលមានភេទទីទៃពីប្រុស ។ តាមវចនានុក្រមខ្មែរនៃពុទ្ធសាសនបណ្ឌិត្យ ពាក្យនេះក្លាយសំនៀងពីពាក្យសំស្ក្រឹត* ***ស្ត្រី*** *ដែលមានភេទផ្ទុយនឹងបុរស ។ ស្រីឬស្ត្រីនេះ នៅក្នុងប្រពៃណីខ្មែរយើងពីបូរាណមក មានតួនាទីធំណាស់ក្នុងសង្គម*(១) *។ ក្នុងប្រពៃណីខ្មែរយើង តែងមានអារម្មណ៍យល់ថា ព្រេងវាសនាប្រពៃ, ចម្រុងចម្រើនសុខសប្បាយ, សុភមង្គល ឋិតនៅក្នុងកណ្ដាប់* ***ស្រីគ្រប់លក្ខណ៍*** (២) *។ ដូចមានសុភាសិតចែងថា «សំណាបយោងដី ស្រីយោងប្រុស»*(៣) *បានសេចក្ដីថា ៖ សំណាបល្អ ដែលគេយកទៅស្ទូងគឺជាជំនួយផ្ដល់ឲ្យដីបណ្ដុះស្រូវបានល្អ ហើយចំណែកស្ត្រី ដែលពេញដោយគុណសម្បត្តិ ជាជំនួយឲ្យប្ដីបានចម្រុងចម្រើន និងប្រកបដោយសុភមង្គល ។*

---

(១) តាមសម្បកក្រៅនៃសង្គមខ្មែរយើង ហាក់ដូចជាឃើញថា ស្ត្រីមានតួនាទីទាបឬរាយរង បើធៀបប្រដូចនឹងបុរស ប្រសិនបើយើងក្រឡេកមើលច្បាប់ទំនៀមនានាដូចជា «ច្បាប់ស្រី» និពន្ធដោយម៉ឺន ម៉ៃ (ច្បាប់ផ្សេង ៗ, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៦ ទំព័រ ១៥–២៩) និង «ច្បាប់ស្រី» និពន្ធដោយហ្លួងអង្គឌួង នា គ.ស. ១៨៣៧ (ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦២, ៣២ ទំព័រ) ។ កវីនិពន្ធទាំងពីររូប ជាបុរស រមែងចង់រក្សាការពារបុព្វសិទ្ធិរបស់ខ្លួនឲ្យខ្ពង់ខ្ពស់ជាងស្ត្រី ។ តែតាមការពិត ក្នុងសង្គមទំនៀមខ្មែរ គឺស្ត្រីទេដែលមានតួនាទីសំខាន់ក្នុងគ្រួសារជាទូទៅ ព្រោះខ្មែរស្ថិតនៅក្នុងសង្គម «មាតាធិបតី» ពោលគឺមាតាជាធំ ។ សូមអាន R. Lingat, *Les régimes matrimoniaux du Sud-Est de l'Asie*, Paris, Maisonneuve, 1952, 2 vol. ។

(២) គ្រប់ ជាពាក្យខ្មែរ សម្គាល់ «ពេញ, ពេញត្រឹម, គ្មានខ្វះ, ឥតចន្លោះ ...» ។ *លក្ខណ៍* មកពីពាក្យបាលី លក្ខណៈ និងសំស្ក្រឹត លក្សណៈ មានន័យ «គ្រឿងសម្គាល់, គ្រឿងចំណាំ, គ្រឿងសង្កេតនាខ្លួនប្រាណ ចង្អុលឲ្យឃើញច្បាស់ថា មានភ័ព្វឬឥតភ័ព្វ, គុណសម្បត្តិ» (*វចនានុក្រមខ្មែរ*, ទំព័រ ១០៨៨) ។

(៣) នួន–ប៊ុត និង ជុំ–មួង, *ប្រមូលភាសិត*, ភ្នំពេញ, ១៩៦១, ទំព័រ ១៨៥ ។

ប្រធានបទ «ស្រីគ្រប់លក្ខណ៍» មានច្រើនពាសពេញក្នុងអក្សរសិល្ប៍ខ្មែរ ដូចជា មាននៅក្នុងរឿងព្រេងនិទាននានា(៤), រឿងល្បែង(៥) និងច្បាប់ផ្សេងៗជាដើម ។

## ១– ប្រពន្ធស្រីគ្រប់លក្ខណ៍ និងប្ដីបុរសកម្ជិល

មានពាក្យទំនៀមខ្មែរមួយថែងថា ៖ «ទ្រព្យគង់ជ្បិតស្រីចេះសំចៃទុកផ្ទះ ជំស្រណុកជ្បិតលក្ខណ៍ស្រីជា» ។

សុភាសិតនេះ បានកត់សម្គាល់នៅក្នុងសេចក្ដីបញ្ចប់នៃរឿងព្រេងខ្មែរ មានចំណងជើងថា «រឿងបុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍»(៦) ។ ចំណងជើងនេះបង្ហាញដោយច្បាស់ ពីដំណើររឿង គឺមានបុរសប្ដីជាមនុស្សខ្ជិល មានភរិយា ជាស្ត្រីមានគុណសម្បត្តិនិងលក្ខណសម្បត្តិជាស្រីគ្រប់លក្ខណ៍ ដែលនាំសុភមង្គលនិងភ័ព្វសំណាងដល់គ្រួសារគ្រប់យ៉ាង...(៧) ។ ដូចមានដំណើររឿងដំណាលខាងក្រោមនេះ ៖

«មានបុរសកំជិលម្នាក់ មានប្រពន្ធគ្រប់លក្ខណ៍ មានកិរិយាមារយាទល្អ ចេះគោរពប្រណិប័តន៍ប្ដី ។ តាំងពីបានគ្នាជាប្ដីប្រពន្ធមក, បុរសកំជិលចេះតែពីដេកដល់ឃ្លានបាយ ទើបក្រោកឡើងស៊ី ។ រួចដេកទៅវិញ សូម្បីថ្នាំជក់ ក៏

---

(៤) ចំពោះការស្រាវជ្រាវលើរឿងព្រេងខ្មែរ សូមអាន Solange Thierry, *Étude d'un corpus des contes cambodgiens traditionnels : Essai d'analyse thématique et morphologique*, thèse de doctorat d'État, Université de Paris V, 1976 ; ហើយនិក្ខេបបទរដ្ឋនេះ បានយកមកបោះពុម្ពផ្សាយឡើងវិញ ដោយដាក់ចំណងជើងថា ៖ *Le Cambodge des contes*, Paris, L'Harmattan, 1985 ។

(៥) ចំពោះការពន្យល់ពាក្យរឿងព្រេងនិងរឿងល្បែង សូមអាន ឃីង ហុកឌី, **ពិជ្ជភាពនូវនៅនៃអក្សរសាស្ត្រខ្មែរ**, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៣, ទំព័រ ៨០–៩៣ ។

(៦) *ប្រជុំរឿងព្រេងខ្មែរ*, ភាគ ១, បោះពុម្ពលើកទី ៧, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៧០, ទំព័រ ១៤៩–១៥១ ។ បកប្រែជាភាសាបារាំងដោយ F. Martini et S. Bernard, *Contes populaires inédits du Cambodge*, Paris, Maisonneuve, 1946, p. 161-165, sous le titre « Histoire du paresseux à l'épouse vertueuse » ។

(៧) S. Thierry, *op. cit.*, p. 297 ។

ប្រពន្ធមួរឲ្យដែរ ។ ប្រពន្ធជាមនុស្សគោរពប្រណិប័តន៍ប្តី មិនមានពាក្យអាក្រក់ទៅលើប្តីសោះ លើកបាយទឹកនិងរបស់អ្វីឲ្យប្តីសុទ្ធតែសំពះ, ដល់ទៅយូរទៅ មានសេចក្តីក្រីក្រខ្លាំងណាស់ នាងនោះរកអ្វីចិញ្ចឹមពុំបានសោះឡើយ, ថ្ងៃមួយ នាងរៀបស្លា ៥ បារី ៥ ម៉ាត់ ចូលទៅក្រាបសំពះប្តី ហើយថា "ខ្ញុំសុំទោសអ្នកប្តី ត្បិតយើងសព្វថ្ងៃក្រណាស់ យើងមិនបានរកស៊ី គ្មានអ្វីទទួលទានទេ សុំឲ្យអ្នកទៅកាប់ឈើធ្វើនង្គ័លរនាស់ ធ្វើស្រែនឹងគេ ត្បិតដល់រដូវធ្វើស្រែហើយ" ។ (...) ចូលដល់ព្រៃរកឈើ, បានឃើញឈើមួយដើម មានមែកសាខាម្ងប់ត្រជាក់ ក៏ដាក់បាយសំណុំ ដឹង ពូថៅ ហើយដេកគងអន្ទាក់ខ្លា មើលទៅលើ និយាយតែម្នាក់ឯងថា "មែកឈើនេះត្រូវធ្វើជាក្បៀងនង្គ័ល, មែកនេះត្រូវធ្វើជាយាម, មែកនេះត្រូវធ្វើជាដង មែកនេះត្រូវជានឹម មែកនេះត្រូវជារនាស់" ។ គ្រាន់តែដេកថាប៉ុណ្ណឹង ពេលឃ្លានបាយក្រោកឡើងស្រាយបាយសំណុំស៊ីៗរួច ដេកដូចមុនទៀត ។ ... »

(បុរសនេះពោលពាក្យដដែលៗ នេះ ជាច្រើនថ្ងៃ រុក្ខទេវតាឮដូច្នោះ ក៏យាងតាមបុរសនេះ ដោយបំណងនឹងសម្លាប់នៅមាត់ជណ្តើរ ។ តែនៅពេលដែលបុរសនេះត្រឡប់មកផ្ទះវិញ, ប្រពន្ធរត់មកទទួលប្តីដល់មាត់ជណ្តើរផ្ទះ ហើយយកទឹកលាងជើងឲ្យប្តី ។) ដោយសិរីសួស្តីប្រពន្ធនោះ ទេវតាចូលមិនចុះ មិនហ៊ានវាយ (ទេវតាបានប្រាប់កំណប់ទ្រព្យ ៤ កន្លែង សូកបុរសនោះមិនឲ្យកាប់ដើមឈើ ហើយបុរសក៏ក្លាយទៅជាអ្នកមានស្តុកស្តម្ភ ដោយមានប្រពន្ធជាស្រីគ្រប់លក្ខណ៍ ។) ។

## ២- ស្រីគ្រប់លក្ខណ៍ និងប្តីទុគ៌ត

ក្នុងរឿងព្រេង «បុរសជីកក្តាម» (៨) គឺនិទានពីបុរសម្នាក់កំព្រាមាតាបិតាស្លាប់ចោល រស់នៅក្រីក្រតោកយ៉ាក ។ បុរសនេះរកស៊ីជីកក្តាមលក់ចិញ្ចឹមជីវិតរៀងរាល់ថ្ងៃ នៅក្រោមខ្ទមអ្នកតានាឦសានផ្ទះ មកចិញ្ចឹមជីវិតតាមការពន្យល់សប្តិពីខ្មោចឪពុកនាយប៉ម្មួយ ។

---

(៨) ប្រជុំរឿងព្រេងខ្មែរ, ភាគ ១, បោះពុម្ពលើកទី ៧, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៧០, ទំព័រ ១៧៥-១៨២ ។

*នៅស្រុកនោះ មានសេដ្ឋីម្នាក់មានកូនក្រមុំច្រើន ហើយបិតាបានរៀបចំឲ្យមានប្ដីអស់ នៅតែនាងពៅប្រកែកមិនព្រមយកប្ដី, សូម្បីសេដ្ឋីបិតានិងម្ដាយបង្ខំយ៉ាងដូចម្ដេច ក៏នាងមិនព្រម ។*

*ព្រឹកថ្ងៃមួយនោះ បុរសទៅជីកក្ដាមដូចសព្វមួង បានក្ដាមមួយ ដើរយកទៅលក់នៅផ្សារ, នាងពៅឃើញ ក៏ទិញក្ដាមពីបុរសនោះ ហើយផ្ដាំថា៖ «ពីថ្ងៃនេះទៅ បើអ្នកបានក្ដាម កុំលក់ឲ្យអ្នកណា ត្រូវអ្នកយកមកលក់ឲ្យខ្ញុំរាល់ថ្ងៃកុំខាន» ។ បងស្រីនាងពៅឃើញបុរសកំសត់ក្រីក្រតោកយ៉ាកយកក្ដាមមកលក់ឲ្យនាងពៅរាល់ថ្ងៃ ហើយនាងហាក់ដូចជាមានកិរិយាស្រឡាញ់បុរសនោះ ជាហេតុនាំឲ្យបងស្រីទាំងនោះយករឿងនេះទៅប្រាប់សេដ្ឋីជាបិតា ៗ ខឹងខ្លាំងក៏ដេញនាងពៅចេញពីផ្ទះ ហើយនាងក៏ទៅនៅជាមួយបុរសកំសត់នោះ ។*

*នាងពៅជាស្រីគ្រប់លក្ខណ៍ បានប្រាប់ប្ដីថា ឈប់ទៅជីកក្ដាមទៀត* (...) *នាងបានទៅតាមប្ដីស្ងាត់ៗ ដើម្បីឲ្យឃើញកន្លែងជីកក្ដាម ។ ពេលប្ដីមិននៅ ដោយចេញទៅកាប់ឧស នាងពៅយកចបទៅជីកកកាយរំលើងនូវទីកន្លែងដែលប្ដីជីកក្ដាម ។*

*លុះព្រឹកឡើង បុរសនោះទៅយកចបទៅជីកក្ដាមទៀត ឃើញទីកន្លែងនោះរលើងខ្ទាត់ខ្ទាយ ហើយឃើញតែសំបកក្ដាមធំប្លែក ហើយក៏យកសំបកក្ដាមនោះមកដាក់ក្រោមផ្ទះ ដោយមិនឲ្យភរិយាដឹង ។ នៅវេលាយប់ចូលដំណេក នាងពៅកាន់ប្រាក់របូតពីដៃជ្រុះមួយណែនទៅក្រោមផ្ទះ ធ្លាក់លើសំបកក្ដាមនោះ តែនាងមិនហ៊ានប្រាប់ឲ្យប្ដីដឹង ដោយគិតថា ចាំព្រឹកសឹមចុះទៅយកប្រាក់មកទុកវិញ ។ លុះព្រឹកឡើង នាងចុះទៅយកប្រាក់មួយណែនដែលធ្លាក់នោះ ស្រាប់តែឃើញប្រាក់ពេញសំបកក្ដាម* (...) *។ បុរសកំសត់និងនាងពៅ ក៏ក្លាយទៅជាអ្នកមានស្ដុកស្ដម្ភ ហើយមហាសេដ្ឋីបិតានាងពៅ ក៏ទទួលស្គាល់ហើយឲ្យមកនៅស្នងត្រកូលសេដ្ឋីបន្ត ។»*

*តាមសំណេរសាស្ត្រាចារ្យ សូឡង់ ចេរី បានចែងថា «បន្ទាប់ពីអន្តរាគមន៍ស្រីគ្រប់លក្ខណ៍មក បណ្ដាលឲ្យមានការផ្លាស់ប្ដូរ៖*

- *ក្ដាមធម្មតា → ជីវភាពដោះស្រាយ*

- ក្ដាមប្លែក → ទ្រព្យសម្បត្តិ, កិត្តិយស»[៩] ។

ក្នុងរឿងសម្លាញ់ពីរនាក់[១០], យើងឃើញមានស្រី ២ បែប គឺមួយជាស្រីគ្រប់លក្ខណ៍ ហើយមួយទៀតជាស្រីខាតលក្ខណ៍ ពោលគឺមានទំនាស់ទំនុយទ្វីភាគរវាងស្រី ២ ប្រភេទនេះ ។ រឿងនេះផ្ដើមឡើង ដោយពាក្យសន្យាថា ៖ «កាលបើយើងមានប្រពន្ធហើយ ឯងក្ដី អញក្ដី បើមានទ្រព្យសម្បត្តិ ត្រូវយើងចិញ្ចឹមគ្នាទៅវិញទៅមក» ។ ក្រោយមក សម្លាញ់មួយមានប្រពន្ធជាស្រីគ្រប់លក្ខណ៍ ហើយសម្លាញ់មួយទៀតមានប្រពន្ធខាតលក្ខណ៍ ។ ជាដំបូងប្ដីប្រពន្ធទាំងពីរគូនេះមានជីវភាពក្រីក្រដូចគ្នា ។

យប់មួយនោះ បុរសនិយាយនឹងប្រពន្ធជាស្រីគ្រប់លក្ខណ៍ថា ៖ «ជាច្រើនឆ្នាំមកហើយ នៅក្នុងសមុទ្រ មានសំពៅអ្នកជំនួញគ្រប់ប្រទេស ខ្លះសុខសប្បាយ ខ្លះលិចលង់របស់ទ្រព្យសព្វសរពើមាសប្រាក់ កប់នៅបាតសមុទ្រនោះច្រើន យើងគិតនាំគ្នាទៅបាចទឹកសមុទ្រនោះឲ្យរីង ក្រអ្វីមាសប្រាក់របស់គ្រប់មុខនោះ (...) ។ យើងទៅបាចទឹកសមុទ្រឲ្យរីង ។»

ចាប់ពីពេលនោះមក ប្ដីប្រពន្ធទាំងពីរនាក់បាចទឹកឥតសម្រាក ហើយឈប់តែពេលបរិភោគបាយថ្ងៃត្រង់ ។ បាចបានចំនួន ៥ ថ្ងៃ ឃើញទឹកសមុទ្រស្រក សណ្ដកហើយ នៅតែខំបាចបន្តទៅទៀតឥតឈប់ឈរតាមការស្នើរបស់ភរិយាគ្រប់លក្ខណ៍ ដោយនាងពោលពាក្យថា «បើដូច្នោះ យើងខំបាចទៅបើយូរណាស់ ត្រឹមកន្លះខែទៀត មុខជារីងហើយ យើងចាប់យកត្រីធំតូចវះធ្វើងៀត ផ្អក ប្រហុក ប៉ូង លក់យកប្រាក់, មួយទៀត យើង ត្រូវកកាយយកប្រាក់មាស តុ ជាស ចានក្បានដ៏មាននៅក្នុងសំពៅទាំងប៉ុន្មាន ដែលលិចលង់មកយូរឆ្នាំនោះ មិនដឹងបើនឹងយកទៅណាអស់ទេ... ។»

ស្ដេចត្រីក័យ ក៏បង្គាប់ត្រីទាំងប៉ុន្មាននោះ ពាំមាសបាន ៥ ក្រឡ ប្រាក់ ៥ ក្រឡ និងតុជាសផ្ដិលចាន ទៅឲ្យបុរសប្ដីប្រពន្ធ អង្វរគេឲ្យលែងបាចទឹកសមុទ្រតទៅទៀត ។

---

(៩) S. Thierry, *op. cit.*, p. 314 ។

(១០) *ប្រជុំរឿងព្រេងខ្មែរ*, ភាគ ១..., ទំព័រ ១១១-១១៥ ។

ថ្ងៃមួយ បុរសជាអ្នកមានសម្បត្តិ បាននិទានប្រាប់ទៅសម្លាញ់ដែលមានប្រពន្ធខាតលក្ខណ៍ ពីហេតុការណ៍ដែលខ្លួនក្លាយជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភនោះ ។ ដឹងដូច្នោះហើយ ក៏បុរសនោះក៏នាំប្រពន្ធទៅធ្វើតាមសម្លាញ់ខ្លួនតែផ្ទុយទៅវិញ ឥតបានទទួលលទ្ធផលអ្វីទាំងអស់ ដោយប្រពន្ធជាស្រីខាតលក្ខណ៍ ។ អ្នកទាំងពីរនេះឈ្លោះប្រកែកគ្នា ហើយលះបង់បំណងពង្រីង ទឹកសមុទ្រ ។

ក្នុងរឿង **មាយើង**(១១) នេះ ខុសពីរឿងព្រេងព្រេងមុន ៗ ដែលជានិទានជាពាក្យរាយ ។ ឯចំណែករឿងមាយើង ជារឿងល្បែង និពន្ធជាកាព្យឃ្លោងគឺមានបទកាកគតិ, ព្រហ្មគីតិ, ពំនោល និង កុជង្គលីលា(១២) ។ នៅក្នុងរឿងនេះ បង្ហាញពីភាពផ្ទុយគ្នា រវាងប្រពន្ធគ្រប់លក្ខណ៍ និងប្រពន្ធកញ្ជើធ្លុះ ។ នាងទី ១ ជាស្រីគ្រប់លក្ខណ៍ ជាភរិយានាយសំពៅម្នាក់ ហើយនាយសំពៅនេះបានដូរប្រពន្ធខ្លួនជាមួយនឹងប្រពន្ធបុរសកំសត់ ដែលមានរូបសម្បត្តិល្អ តែជាស្រីកញ្ជើធ្លុះ ។ បន្ទាប់ពីបានប្រពន្ធជាស្រីគ្រប់លក្ខណ៍មកបុរសនោះក៏ក្លាយជាអ្នកមានស្ដុកស្ដម្ភ និងទៅជាមន្ត្រីធំក្នុងបរមរាជវាំងទៀត ។ ឯចំណែកគហបតីនោះវិញ ក្រោយពីបានប្រពន្ធកញ្ជើធ្លុះមក ក៏ចុះក្របន្តិចម្ដង ៗ រហូតដល់ទៅជាស្មូមយាចក ដូចមានដំណើររឿងសង្ខេបខាងក្រោមនេះ ៖

« នៅនគរពារាណសី មានស្ដេចមួយអង្គ ព្រះនាម ព្រហ្មទត្ត មានមហេសីប្រកបរូបសម្បត្តិល្អ ។ ព្រះរាជាអង្គនេះគ្រប់គ្រងនគរ ប្រកបដោយទសពិធរាជធម៌ ហើយប្រជានុរាស្ត្ររស់នៅដោយសុខសាន្តនិងសម្បូណ៌សប្បាយ ។

---

(១១) ប្រជុំរឿងព្រេងខ្មែរ, ភាគ ៤, បោះពុម្ពលើកទី ៣, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, ទំព័រ ៣១–៦០ ។ មាយើង, Paris, Plon-Nourrit, 1902, 64 p. ; É. Aymonier, *Textes khmèrs*, Saigon, 1878, p. 64–68, 255–266 ។

(១២) ចំពោះកំណាព្យ សូមអាន អៀង–សាយ, មេកាព្យ, ភ្នំពេញ, បណ្ណាគារ ម៉ី–សុខ, ១៩៦៦, ៥៧ ទំព័រ, គីម–សែត, ក្បួនតែងកាព្យ, ភ្នំពេញ, បណ្ណាគារ រស្មីកម្ពុជា, គ្មានកាលបរិច្ឆេទ, ៤៨ ទំព័រ ។ J. Rœské, « Métrique khmère, *bat* et *kalabat* », *Anthropos* VIII (1913), p. 670–687 et 1026–1043 ; J. Jacob, « Some Features of Khmer Versification », in : *In memory of J. R. Firth*, London, Longmans, 1966, p. 227–241 ។

នៅនគរនេះ មានបុរសម្នាក់រស់នៅក្នុងភាពក្រីក្រតោកយ៉ាកជាពន់ពេកជាមួយនឹងប្រពន្ធ ដែលមានរូបរាងល្អ តែចិត្តអាក្រក់ នាំឲ្យអ្នកជិតខាងស្អប់ ។

ថ្ងៃមួយ បុរសនោះទៅនេសាទត្រីជាមួយភរិយាក្នុងភាពក្រៀមក្រំ ដោយខ្លួនក្រីក្រពេក ។ កញ្ជើគាត់ធ្លុះធ្លាយដោយអន្ទើ តែប្រពន្ធមិនគិតជួសជុលសោះឡើយ ។ ពេលដែលជញ្ជាត់បានត្រី ប្រពន្ធបុរសនោះ យកទៅដាក់ក្នុងកញ្ជើធ្លុះ, ត្រីក៏ធ្លាក់ចុះទៅក្នុងទឹកវិញ ដោយនាងនោះពុំមានយកចិត្តទុកដាក់សោះឡើយ ។ ការនេសាទនេះប្រព្រឹត្តនៅតាមឆ្នេរ ជិតសំពៅធំមួយ ក្រោមខ្សែភ្នែកនាយសំពៅនិងភរិយា ។ ដោយឃើញត្រីជ្រុះចេញពីកញ្ជើដូច្នោះ ភរិយានាយសំពៅទ្រាំពុំបាន ក៏ស្រែកប្រាប់ឲ្យចុកប្រហោងកញ្ជើ ជាហេតុធ្វើឲ្យនាយសំពៅខឹងស្តីបន្ទោសប្រពន្ធ ហើយយកនាងទៅដូរជាមួយនឹងប្រពន្ធបុរសកំសត់ ដែលមានរូបឆោមល្អ ។ ប្រពន្ធនាយសំពៅជាស្រីគ្រប់លក្ខណ៍ចុះពីសំពៅ ដោយឥតរុញរា ហើយយកដៃម្ខាងកាន់ដៃបុរសកំសត់ជាប្តីរួចដៃម្ខាងទៀតកាន់កញ្ជើធ្លុះនេះ ។ នាងបោចស្មៅកឈើមកចុកប្រហោងកញ្ជើឲ្យជិត ហើយនាងបន្តដំណើរតាមមាឃើងជាប្តី ជញ្ជាត់ត្រីបានច្រើនពេញកញ្ជើទើបត្រឡប់ទៅផ្ទះ ។

មកដល់ផ្ទះ នាងស្រីគ្រប់លក្ខណ៍ប្រាប់ប្តីឲ្យយកត្រីមួយចំនួន ទៅចែកចាយអ្នកជិតខាង ៗ ងឿងឆ្ងល់ខ្លាំងពីការប្រែប្រួលអាកប្បកិរិយាមាឃើង ។ តែដោយឃើញបុរសនេះមានភរិយាថ្មីជាស្រីគ្រប់លក្ខណ៍ ទើបយល់ហេតុការណ៍នេះ ។

ថ្ងៃមួយ មាឃើងចេញទៅព្រៃរកកាប់ឧសសម្រាប់ដណ្តាំបាយ ។ តែឧសទាំងនោះ គឺជាឈើចន្ទន៍ក្រឹស្នាក្ខាំពាក់ ដែលជាឈើមានតម្លៃ អាចយកទៅលក់បានកម្រៃច្រើន ។ នាងប្រពន្ធធ្លាប់ធ្វើជំនួយ ស្គាល់តម្លៃឈើក្រអូបនេះ ក៏ប្រាប់ឲ្យប្តីយករទេះទៅដឹកឈើចន្ទន៍ក្រឹស្នាក្ខាំពាក់ឲ្យអស់ យកមកលក់តាមតម្លៃទីផ្សារ បានប្រាក់កាសច្រើន ក្លាយទៅជាអ្នកមានស្តុកស្តម្ភ អាស្រ័យដោយប្រពន្ធជាស្រីគ្រប់លក្ខណ៍ ។

នាងបានជួយលើកទឹកចិត្តប្តីឲ្យខំរៀនរត់ រហូតដល់លឿនជាងល្បឿនសេះរត់ទៅទៀត ដោយឥតហត់ ។ ដោយនាងភរិយាស្គាល់មហាមន្ត្រីម្នាក់ ក៏បាន

*បញ្ចូលប្ដីឲ្យបានទៅធ្វើជាអ្នកបម្រើស្ដេចក្នុងបរមរាជវាំង ហើយព្រះរាជាសន្មតនាមថា មាយើង ។*

*ថ្ងៃមួយ ស្ដេចព្រហ្មទត្តទ្រង់ចង់ទៅប្រពាតព្រៃ ក៏បញ្ជាឲ្យមន្ត្រីរាជាមាត្យរៀបចំដំណើរកំសាន្តនេះ ។ មាយើងក៏ឲ្យប្រពន្ធរៀបតណ្ដាប់ ដើម្បីធ្វើដំណើរតាមក្បួនដង្ហែស្ដេចប្រពាតព្រៃព្រឹក្សា ។*

*ព្រឹកឡើង ព្យូហយាត្រាបានរៀបចំស្រេច, ព្រះមហាក្សត្រគង់នៅកណ្ដាលពួកពលយោធា ក៏ចេញដំណើរ ។ ពេលទៅដល់ព្រៃ ស្ដេចបញ្ជាអាជានេយ្យឲ្យបោលលឿនស្ទេវ ជាហេតុនាំឲ្យពួកមន្ត្រីយោធាតាមមិនទាន់ព្រះអង្គ គឺមានតែមាយើងម្នាក់គត់ រត់តាមទាន់អាជានេយ្យព្រះរាជា ។*

*លុះដល់ក្រោមជ្រៃធំមួយ ស្ដេចទ្រង់បញ្ឈប់ជំនិះសម្រាកព្រះអង្គ ។ នៅដាច់ឆ្ងាយពីមន្ត្រីពលយោធា ហើយឃើញតែមាយើងម្នាក់គត់ ។ យល់ដូច្នោះ ព្រះរាជាប្រទាននាម «មាយើង» ឲ្យបុរសនោះ ។ ព្រះអង្គចាំអស់ពេលយូរដល់ថ្ងៃត្រង់ មិនឃើញមន្ត្រីយោធាមកដល់ ហើយព្រះអង្គឃ្លានក្រយាស្ងោយ ព្រះរាជាក៏សោយអាហារនិងទឹកអប់ផ្កា ដែលរៀបចំដោយស្រីគ្រប់លក្ខណ៍ជាករិយាមាយើង ហើយព្រះអង្គមានរសជាតិឈ្ងុយឆ្ងាញ់ ដូចក្រយាសោយនៅបរមរាជវាំងដែរ ។*

*ក្រោយពីសោយអាហារហើយ ព្រះអង្គក៏ផ្ទំលើភ្លៅមាយើង ហើយស្ដេចសន្យានឹងនិទានរឿងប្រទានមាយើងស្ដាប់ ។ ព្រះអង្គទើបតែនិទានរឿងព្រេងបានបន្តិច ក៏ផ្ទំលក់លើភ្លៅមាយើង ជាហេតុធ្វើឲ្យរុក្ខទេវតាទាំងនោះ ដែលនៅចាំស្ដាប់រឿងខឹងយ៉ាងខ្លាំង ដោយយល់ថា ស្ដេចព្រហ្មទត្តមិនប្រកាន់ពាក្យសត្យ ។ ទេវតាសន្ទនាគ្នាហើយសម្រេចថា ៖*

«ច្នោះយើងអត់ថ្វី ស្ដេចពាលអប្រិយ<br>
កាច់មែកជ្រៃថ្នាត់ ទំលាក់ទៅលើ<br>
សង្កត់មហាក្សត្រ ឲ្យស្ដេចបង់បាត់<br>
ព្រះជន្មជីវី ។<br>
ថាបើពុំទាន់ នៅនេះក្រែងខាន<br>
ស្ដេចទៅបុរី យើងកាច់ខ្លោងទ្វារ

សង្កត់ចក្រី ព្រហ្មទត្តតិរ្ថិយ
ឲ្យក្ស័យជន្មា ។
ថាបើបានទៅ លុះស្ដេចចូលទៅ
ដល់លើក្រឡា បន្ទំរម្យរ័តន៍
តែស្ងាត់និន្ទ្រា យើងប្រែក្រឡា
ជាពស់ទៅខាំ ។
ស្អប់ស្ដេចកុហក ថាហើយដេកលក់
ឲ្យតែយើងចាំ មាយើងងងុយ
អង្គុយតែចាំ ឮពាក្យងាំ ៗ
ងាំ ៗ នោះណា ។ (១៣) »

*មាយើងឮការសន្ទនាទេវតា ក៏ដាស់ព្រះរាជា ហើយបានទូលព្រះអង្គតាមដំណើរ ។ ស្ដេចប្រញាប់ប្រញាល់ឡើងអាជានេយ្យ យាងចេញយ៉ាងរួសរាន់ ពេលនោះ មែកជ្រៃបាក់ចំកន្លែងដែលស្ដេចព្រហ្មទត្តផ្ទំ ។ ស្ដេចបានគេចរួចជីវិតពីបំណងធ្វើឃាតរបស់ពួកទេវតា ។ បន្ទាប់មក ស្ដេចបានគេចរួចជីវិតពីខ្លោងទ្វាររាំងរលំបំបាក់ដោយពួកទេវតាទៀត ។*

*ដល់ពេលយប់មាយើងមកនៅយាមរាំង ក្នុងក្រឡាបន្ទំស្ដេច បានកាប់សម្លាប់ពស់ធំប៉ុនដើមត្នោត ដែលទេវតាបានកាឡាខ្លួនមក បំណងធ្វើចឹកសម្លាប់ស្ដេចព្រហ្មទត្ត ។ ឈាមពស់នោះ ខ្ទាតទៅលើទ្រូងព្រះមហេសីព្រះរាជា ។ មាយើងមិនហ៊ានជូតឈាមលើទ្រូងព្រះមហេសីនឹងដៃ ហើយមាយើងក៏យកអណ្ដាតខ្លួនទៅលិឍឈាមនោះដោយក្ដីគោរព ។ ពេលនេះមហេសីព្រះរាជាភ្ញាក់ឡើងហើយទូលស្ដេចពីអាកប្បកិរិយាមាយើង ធ្វើឲ្យព្រះអង្គខ្ញាល់យ៉ាងខ្លាំង ហើយបញ្ជាឲ្យពេជ្ឈឃាតយកមាយើងទៅសម្លាប់ទាំងយប់ ក្រៅពីបរិវេណរាំង ។ នាយទ្វារទាំងបួនទិស មិនព្រមបើកទ្វារឲ្យពេជ្ឈឃាតនៅពេលយប់ ហើយអ្នកទោសមិនទាន់បានកាត់ក្ដីតាមគន្លងច្បាប់*

(១៣) ប្រជុំរឿងព្រេងខ្មែរ, ភាគ ៤, ... ទំព័រ ៤៣ ។

*ពីបូរាណ ។ នាយទ្វារនិមួយៗ បាននិទានរឿងមួយៗ ដែលទាក់ទងនឹងការសម្លាប់ដោយគ្មានការវិនិច្ឆ័យទោស ។*

*លុះព្រឹកឡើង ស្តេចភ្ញាក់ពីបន្ទំនឹកស្តាយ ដោយបញ្ជាឲ្យពេជ្ឈឃាតយកមាយើងជាអ្នកបម្រើដ៏ស្មោះត្រង់ មានគុណលើព្រះអង្គ ទៅសម្លាប់ដោយឥតវិនិច្ឆ័យ ។ ព្រះអង្គក៏បញ្ជាអាមាត្យទៅឃាត់ពេជ្ឈឃាត ហើយឲ្យនាំមាយើងមកជួបព្រះអង្គ ដើម្បីសាកសួរហេតុផល ។ មាយើងបានរាយរាប់តាមដំណើរហើយ ទើបស្តេចឲ្យទៅយកខ្មោចពស់មកមែន ដូចសាសព្ទចៅមាយើង ។ កាលនោះ ព្រះអង្គជឿជាក់ ទើបដឹងគុណមាយើង ហើយតែងតាំងមាយើងជាមន្ត្រីធំ ។*

*នៅជំពូកទី ២ នៃរឿងនេះ និទានពីនាយសំពៅដែលរស់នៅជាមួយប្រពន្ធមានសម្ផស្សល្អ តែជាស្រីកញ្ជើធ្លុះ ខ្ជះខ្ជាយសម្បត្តិទ្រព្យប្តី ដោយឥតគិតគូរ ។ ពេលនាងមានកូនខ្ចី នាងយកកំណាត់សូត្រជូតលាមកកូន ហើយបោះចោល ដោយឥតសំចៃគិតបន្តិចបន្តួចសោះ ។ ក្រោយមក នាយសំពៅនិងនាងនេះអស់ទ្រព្យសម្បត្តិ រហូតដល់ក្លាយខ្លួនក្រតោកយ៉ាកយ៉ាងខ្លាំង ហើយនាងបង្ខំឲ្យប្តីទៅសូមទានគេដើម្បីចិញ្ចឹមជីវិត ។ ថ្ងៃមួយនោះ ប្តីប្រពន្ធទាំងពីរនេះទៅសូមទានដល់ផ្ទះមាយើង ហើយករិយាមាយើងស្គាល់នាយសំពៅ ដែលក្លាយខ្លួនជាស្មូមយាចកដូច្នោះ ក៏ពោលពាក្យថា ៖*

« (...) ឱនាយសំពៅ ម្តេចដើរសុំទាន ។
ប្តូរផ្តាច់បោះបង់ អញឥតមានស-
ង្ស័យអញស្មោះស្មាន នឹងកើតរបស់
ស័ក្តិយសធនធាន ឥឡូវម្តេចប្រាណ
ប្រែខ្លួនទទេ ។
ល្អពេកមុខចៅ ចៅនាយសំពៅ
ដើរសុំទានគេ ស្រឡាញ់ប្រពន្ធ
ល្អលន់មុខមេ កញ្ជើធ្លុះទេ
ល្អពេកប្រាកដ ។
នេះហេតុ**លក្ខណ៍ស្រី** គេចំរើនប្តី

បរិបូណ៌បាទបទ ស្រីយើងចង្រៃ
ពេកក្រៃប្រាកដ នៅនឹងអ្នកខ្សត់
ប្រែជាអ្នកមាន ។ (១៤) »

*រឿងមាយើងនេះ បង្ហាញពីព្រេងវាសនាជោគជ័យសិរីសួស្ដី អាស្រ័យទៅលើ « លក្ខណ៍ » របស់ស្ត្រី ។ ប្រសិនបើប្រពន្ធនោះជាស្រីគ្រប់លក្ខណ៍, ប្ដីនឹងទៅជាមនុស្សមានបុណ្យសក្តិ មានសិរីមង្គល វិបុលសុខ ហើយប្រសិនបើប្រពន្ធនោះជាស្រីខាតលក្ខណ៍ឬកញ្ជើធ្លុះ, ប្ដីនឹងក្លាយជាជនមានទុក្ខលំបាក និងក្រីក្រតោកយ៉ាក ។*

## ៣- ស្រីគ្រប់លក្ខណ៍ និងប្ដីរូបអាក្រក់ឬពិការ ឬជាសត្វតិរច្ឆាន

### ក- ប្ដីរូបអាក្រក់ឬពិការ

*តួសំខាន់ ជាប្ដីរស់នៅជាបណ្ដោះអាសន្ន ក្នុងសំបកស្រោម ជារូបកាយអាក្រក់ចំឡែក ឬជាសត្វតិរច្ឆាន ហើយបានចាកចេញនៅទីបញ្ចប់ ។ នៅក្នុងរឿងព្រេងមួយ មានចំណងជើងថា* **សុវណ្ណសិរសា** (១៥) *តួអង្គសំខាន់មានតែក្បាលឥតរាងកាយ ។ ចៅសុវណ្ណសិរសាចង់បានជាភរិយាបុត្រីពៅស្ដេចព្រហ្មទត្ត ។ បញ្ជាឲ្យសាងស្ពានមាសស្ពានប្រាក់ ទើបសុខព្រះទ័យប្រគល់ឲ្យបុត្រីពៅ ។ ជាស្រីគ្រប់លក្ខណ៍ ក៏សុខចិត្តទទួលចៅសុវណ្ណសិរសាជាស្វាមីតាមពាក្យសន្យារបស់ព្រះបិតាដោយពោលថា ៖*

*« បើព្រះអង្គនិងឲ្យខ្ញុំមានស្វាមិ្យ ទោះប្បីគ្មានជើងមានតែក្បាល ប្រការតួចម្ដេច ៗ ខ្ញុំតាមព្រះបន្ទូលនិងឲ្យស្ដេចបងព្រះបន្ទូលម្ដេច »* (១៦) ៗ

---

(១៤) ប្រជុំរឿងព្រេងខ្មែរ, ភាគ ៤, ... ទំព័រ ៥៩ ។

(១៥) *សុវណ្ណសិរសា,* សាស្ត្រាស្លឹករឹត តម្កល់នៅបណ្ណាល័យជាតិក្រុងប៉ារីស ចុះលេខបញ្ជី Indochinois 165 B /cambo. 87/, ៤ ខ្សែ ។

(១៦) *សុវណ្ណសិរសា,* ខ្សែ៣ ; សន្លឹក « តំ » (អក្ខរាវិរុទ្ធដើម), កែតាមអក្ខរាវិរុទ្ធទំនើប ៖ « បើព្រះអង្គនឹងឲ្យខ្ញុំមានស្វាមី ទោះបីគ្មានជើងមានតែក្បាលប្រការដូចម្ដេច ៗ ខ្ញុំតាមព្រះបន្ទូលនឹងឲ្យស្ដេចបងព្រះបន្ទូលម្ដេច » ។

សេចក្តីសង្ខេបនៅខាងក្រោមនេះ បង្ហាញពីស្រីគ្រប់លក្ខណ៍ ដែលសុខចិត្តទទួលតាមពាក្យសត្យរបស់បិតា ៖

«ក្នុងរជ្ជកាលស្តេចព្រហ្មទត្តសោយរាជនៅនគរពារាណសី, ក្នុងភូមិមួយឈ្មោះបញ្ចាលគ្រាម មានប្តីប្រពន្ធជាអ្នកក្រីក្រ ហើយភរិយាឈ្មោះនាងចន្ទាបណ្ឌិត ។ យប់មួយ នាងយល់សុបិនឃើញកង្កែបមួយ មាននាមថារាហូអសុរិន្ទ ហោះក្នុងអាកាសទៅលេបព្រះចន្ទ ហើយមានចំណែកមួយធ្លាក់មកលើផ្ចិតនាង ។ ព្រឹកឡើង នាងទៅរកហោរឲ្យទស្សន៍ទាយលើសុបិនចំឡែកនេះ ។ ហោរបានទាយថា នាងនឹងមានគភ៌ ហើយនឹងបានបុត្រាមួយមានតែក្បាលឥតខ្លួន ។ នាងមានគភ៌បាន ៤ ខែ ប្តីក៏ស្លាប់ចោលនាងដូចទំនាយហោរ ។ លុះគ្រប់ខែ នាងបានប្រសូតបុត្រាល្អប្រិមប្រិយ មានតែក្បាលឥតខ្លួន ហើយនាងបានឲ្យនាមថា "សុវណ្ណសិរសា" ។

ក្រោយមក សុវណ្ណសិរសាចេញដំណើរជាឈ្មួញសំពៅទៅជួញដូរ បានជួបនឹងកោះមួយ ហើយក៏ចុះនៅទីនោះដាំត្រសក់, ឪឡឹក, ដំឡូង ជាដើម ។ ពេលមួយនោះ មាននាគីពីរនាក់ជាបុត្រីស្តេចនាគ មកលេងកោះនោះ ហើយបានបោចលេងដំណាំក្នុងចំការចៅសុវណ្ណសិរសា ៗ មិនទាន់ ។ នាងនាគីយល់កំហុសរបស់ខ្លួន ក៏យកមាស ៨ អសង្ខេយ្យមកឲ្យចៅសុវណ្ណសិរសាជាសំណង ។

ក្លាយខ្លួនជាអ្នកមានដូច្នោះហើយ, សុវណ្ណសិរសាចង់បានភរិយា គឺនាងពៅជាបុត្រីស្តេចព្រហ្មទត្ត ។ សុខព្រះទ័យ លុះណាតែសុវណ្ណសិរសាសង់ស្ពាន ២ បានតែមួយរាត្រី គឺមួយជាមាស ហើយមួយទៀតជាប្រាក់ ឆ្លងពីផ្ទះសុវណ្ណសិរសារហូតមកដល់បរមរាជវាំង[១៧] ។ ពេលនោះ ទេវតាបានចុះជួយសាង បានសម្រេចដូចបំណង ។ ដោយឃើញដូច្នោះ ស្តេចព្រហ្មទត្តក៏ព្រមប្រគល់បុត្រីពៅ នាម នាងគន្ធរាជ ឲ្យចៅសុវណ្ណសិរសា ។

---

(១៧) ប្រធានបទការសាកល្បងសាងស្ពានមាសស្ពានប្រាក់តែមួយយប់បាននេះ មាននៅពាសពេញក្នុងរឿងព្រេងខ្មែរយើង ឧទាហរណ៍ រឿង ចៅក្តាំងចាយនិងម្ចាស់សត្រីសែនជិបតី, បណ្ណាគារភ្នំពេញ, ១៩៥៤, ១៣៤ ទំព័រ ។ cf. F. Martini et S. Bernard, *op. cit.*, p. 95 ។

*ដោយយល់ភាពអាម៉ាស់អាស្រូវដូច្នេះ, ប្រជារាស្ត្របះបោរឡើងសុំឲ្យស្តេចយកចៅសុវណ្ណសិរសាទៅសម្លាប់ចោល ។ តែព្រះឥន្ទចុះពីឋានសួគ៌ មកចោទ ៤ ប្រស្នាឲ្យស្តេចព្រហ្មទត្តដោះស្រាយ, ប្រសិនបើដោះស្រាយមិនរួចទេគឺត្រូវស្លាប់ ។ ស្តេចពុំអាចដោះប្រស្នាទាំងនេះបាន ហើយភ័យ ក៏សុំឲ្យសេនាមុខមន្ត្រីករិបណ្ឌិតជួយដោះ ក៏ដោះពុំរួចទៀត ។ ស្តេចព្រហ្មទត្តសុខព្រះទ័យទៅពឹងចៅសុវណ្ណសិរសាឲ្យជួយដោះប្រស្នា ។ ចៅនេះបានចាកចេញពីស្រោម ក្លាយជាមនុស្សមានរូបកាយល្អប្លែក មកជួយដោះប្រស្នារួចស្រួលនៅចំពោះមុខប្រជារាស្ត្រទូទៅ ។ ស្តេចព្រហ្មទត្តក៏ប្រគល់រាជសម្បត្តិទៅសុវណ្ណសិរសា ឲ្យសោយរាជ្យស្នងព្រះអង្គតទៅ ។»*

*មានរឿងល្បែង ២ ទៀត ដែលមានប្រជាប្រិយទូទាំងប្រទេស គឺមួយមានចំណងជើងថា* **ខ្យងសង្ខ**(១៨) *ហើយមួយទៀតឈ្មោះ* **ហៃសង្ខ**(១៩) *គឺជារឿងល្បែង ដែលមានដំណើររឿងប្រហាក់ប្រហែលគ្នា ដូចមានសេចក្តីសង្ខេបខាងក្រោមនេះ ៖*

*« ស្តេចវិមលរាជសោយរាជសម្បត្តិនៅនគរសោឡសមហានគរ ទ្រង់មានមហេសី ២ ហើយ អគ្គមហេសីទី ១ ព្រះនាមចន្ទទេវី, ព្រះនាងមហេសីទី ២ ព្រះនាមឆន្ទា ។ មហេសីទាំង ២ នេះទ្រង់គភ៌ហើយហោរាបានទស្សន៍ទាយថា*

---

(១៨) សង្ខ មកពីបាលី មានន័យថា « ខ្យង » ។ សូមអាន *ខ្យងសង្ខ*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦១, ២៥៦ ទំព័រ ។ រឿងល្បែងនេះតែងឡើងនាមហាសករាជ ១៦៥១ ក្នុងឆ្នាំរកា ៨ រោច (ឯកឆបញ្ចេក) គឺត្រូវនឹង គ.ស. ១៧២៩ ហើយក្រសួងអប់រំ បានបញ្ចូលក្នុងកម្មវិធីសិក្សាអក្សរសិល្ប៍ នៅមធ្យមសិក្សាជាតិ ។ សូមអានសាស្ត្រាស្លឹករឹត *ខ្យងសង្ខ* តម្កល់នៅបណ្ណាល័យសាលាបារាំងចុងបូព៌ា ចុះលេខ ៨៩, ៨ ខ្សែ ។

(១៩) *ហៃសង្ខ*, ភ្នំពេញ, បណ្ណាគារ គីម–គី, ១៩៥៥, ៨ ខ្សែ (ហៃ មកពីពាក្យសៀម ហាយ = « ខ្យង ») ។ អ្នកស្រី ប៉ូរេ–ម៉ាស្ពេរ៉ូ បានស្រង់កត់ត្រា តាមអក្សរសិល្ប៍សំដីរឿង *ហៃសង្ខ* ក្នុងនិក្ខេបបទអ្នកស្រីថា « ហៃសង្ខ កើតក្នុងស្រោមខ្យង ហើយបានរស់នៅឋានភុជង្គនាគ ។ ក្រោយមកបានស្លៀកពាក់ស្រោមងោះ ហើយនៅទីបញ្ចប់ បានរៀបការជាមួយបុត្រីពៅស្តេច » ដែលជាស្រីគ្រប់លក្ខណ៍ ។ សូមអាន É. Porée-Maspero, *Étude sur les rites agraires des Cambodgiens*, t. II, Paris, 1969, p. 526 ។

ព្រះនាងមហេសីទី ១ នឹងមានបុត្រា ១ នឹងបានសោយរាជ្យស្នងទៅអនាគត ។ ព្ធដូច្នោះ នាងឆន្ទាប្រណែននឹងអគ្គមហេសី, ក្រោយមក នាងឆន្ទាប្រសូតបានបុត្រី ១ ។ ឯនាងចន្ទទេវី ប្រសូតបានខ្យងសង្ខ ធ្វើឲ្យព្រះរាជាខ្ញាល់ ហើយក៏បំបរបង់នាងឲ្យចេញពីវាំងដោយការញុះញង់របស់នាងឆន្ទា ។

រស់នៅក្នុងព្រៃ, ខ្យងស័ង្ខរមែងចេញពីស្រោម នៅពេលដែលមាតាចេញទៅរកស៊ីខាងក្រៅផ្ទះ ។ ថ្ងៃមួយនោះ នាងចន្ទទេវីបានឃើញកូនចេញពីស្រោមខ្យងស័ង្ខ ក៏ទៅយកស្រោមនោះមកកម្ទេចចោល ។

ដោយឃើញខ្យងស័ង្ខកុមារមានរូបកាយល្អ, នាងឆន្ទាក៏ទូលស្ដេចឲ្យយកចាប់កុមារយកទៅសម្លាប់ ។ ពេជ្ឈឃាតចងកុមារសណ្ដូននឹងថ្មហើយពន្លិចក្នុងទឹកសមុទ្រ ។ ខ្យងស័ង្ខកុមារបានរស់នៅជាមួយស្ដេចកុជង្គនាគមួយរយៈ ហើយបន្ទាប់មក បានយក្ខិនីយកទៅធ្វើជាកូនចិញ្ចឹម ។ ថ្ងៃមួយ ចេញទៅលេងព្រៃ, ខ្យងស័ង្ខកុមារក៏ចុះទៅមុជទឹកក្នុងស្រះប្រាក់-ស្រះមាស ដែលមាតាចិញ្ចឹមមិនឲ្យទៅទីនោះ ហើយយកដំបងប្រត់ទិព្វ និងពាក់ស្រោមង៉ោះ[(២០)] ហោះលើមេឃដោយគ្រវីប្រត់ទិព្វ ។

ខ្យងស័ង្ខកុមារហោះទៅដល់នគរព្រះបាទសាមល ។ ស្ដេចអង្គនេះមានបុត្រីក្រមុំ ៧ អង្គ, នាង ៦ អង្គរើសព្រះស្វាមីបានក្នុងចំណោមបុត្រាស្ដេចចំណុះទាំង ១០១ លើកលែងតែនាងពៅម្នាក់គត់ មិនទាន់រើសស្វាមីបានក្នុងចំណោមបុត្រស្ដេចចំណុះនិងកូនប្រជារាស្ត្រក្នុងនគរ ។ តែទីបញ្ចប់ នាងរើសយកង៉ោះជាស្វាមី ជាហេតុធ្វើឲ្យស្ដេចបិតាខ្ញាល់បំបរនាងឲ្យចេញពីបរមរាជវាំងជាមួយស្វាមីង៉ោះ ។

ស្ដេចបិតាបានធ្វើវិញ្ញាសាល្បងបុត្រាប្រសាទាំងអស់ គឺមានង៉ោះក្នុងចំណោមនោះដែរ ។ ដំបូង ស្ដេចល្បងឲ្យបុត្រាទាំងនោះបរបាញ់សត្វ, បន្ទាប់ ល្បងឲ្យទៅនេសាទត្រី ។ ខ្យងស័ង្ខកុមារចេញពីស្រោមង៉ោះ ដោយមានរូបឆោមល្អដូចទេវតាចេញទៅរកសត្វ ។ ដោយឫទ្ធិអំណាច ខ្យងស័ង្ខ

---

(២០) យក្សមានរូបខ្មៅ ។ តាមសំដីប្រជាប្រិយ ប្រសិនបើគេហៅជនណាម្នាក់ថា « អាង៉ោះ » គឺបុគ្គលនោះជាមនុស្សល្ងង់ខ្លៅបំផុត, ល្ងីល្ងើ ហើយមានរូបកាយអាក្រក់ឥតឧបមា ។ សូមអាន É. Porée-Maspero, *op. cit.*, p. 526 ។

*កុមារចាប់បានសត្វបានដូចបំណង ។ ចំណែកឯប្ដីបង ៗ នាង ចាប់មិនបាន សោះ ក៏ជួបខ្យងស័ង្ខកុមារ ហើយក៏សុំសត្វខ្លះ តែជាថ្នូរសុខចិត្តឲ្យខ្យងស័ង្ខកុមារកាត់ច្រមុះបន្តិច ហើយខ្យងស័ង្ខកុមារចូលក្នុងស្រោមវិញ ហើយយកសាច់ម្រឹគមកថ្វាយបិតាមុនបុត្រា ៦ អង្គទៀត ។ ល្បងលើកទី ២ ឲ្យទៅនេសាទត្រី ហើយរើះបានត្រីមកដល់វាំងមុនបង ៗ ទាំង ៦ អង្គ ៗ មកដល់វាំងក្រោយរើះ ហើយត្រីនោះទៀតសោត អន់សាច់ ព្រោះដោយធ្វើដំណើរយូរពេក ព្រមទាំងខែបត្រចៀកបន្តិចទៀត ព្រោះជាថ្នូរនឹងត្រីដែលខ្យងស័ង្ខកុមារឲ្យ ។*

*ថ្ងៃមួយ ព្រះឥន្ទ្របានបញ្ជាឲ្យព្រះបាទសាមលមកលេងឃ្លីកូនគោលជាមួយព្រះអង្គ ។ បុត្រប្រសាទាំង ៦ អង្គមិនហ៊ានល្បងនឹងព្រះឥន្ទ្រ ។ ស្ដេចក៏ឲ្យរើះមកលេងជំនួសព្រះអង្គ ។ ពេលនោះ ខ្យងស័ង្ខកុមារចេញពីស្រោមរើះហើយចេញមកលេងល្បងជាមួយព្រះឥន្ទ្រ ៗ លេងចាញ់ព្រះរាជកុមារ ។ ស្ដេចយល់រូបពិតរបស់កូនប្រសា ត្រេកអរខ្លាំង ហើយប្រគល់រាជសម្បត្តិឲ្យខ្យងស័ង្ខកុមារសោយរាជ្យស្នង ...» ។*

## ១- ស្វាមីជាសត្វ

*តួអង្គសំខាន់ក្នុងរឿងកើតក្នុងស្រោមជាសត្វតិរច្ឆាន មានជាច្រើនក្នុងអក្សរសិល្ប៍ខ្មែរប្រជាប្រិយ ដូចមានឧទាហរណ៍ខ្លះ ៗ ខាងក្រោមនេះ ៖*

*នេះជាសេចក្ដីសង្ខេបរឿងព្រេងមួយមានចំណងជើងថា* **ចៅក្រពត** (២១) ៖

*«មានតាចាស់យាយចាស់ប្ដីប្រពន្ធ រស់នៅចិញ្ចឹមជីវិត ជារៀងរាល់ថ្ងៃដោយរបរនេសាទ ។ ថ្ងៃមួយ យាយតាទាំងពីរនាក់ទៅដញ្ជាត់ត្រីពីព្រលឹមរហូតដល់ល្ងាច បានតែក្រពតមួយប៉ុណ្ណោះ ក៏យកក្រពតនោះមកចិញ្ចឹម ។*

(២១) ចៅក្រពត, Paris, Imprimerie cambodgienne, Plon-Nourrit, 1903, 26 p. ។ សូមអានសាស្ត្រាស្លឹករឹតតម្កល់នៅបណ្ណាល័យជាតិក្រុងប៉ារីស, ចុះលេខ Indochinois 86 I. Cf. Au Chhieng, *Catologue du fonds khmer*, Paris, Imprimerie nationale, 1953, p. 14 ; É. Porée-Maspero, *op. cit.*, p. 442 ។

*ពេលយាយតាមិននៅ ចៅក្រពតចេញពីស្រោមមកក្រៅ ជួយដេញមាន់ទាំងឡាយ ដែលមកស៊ីស្រូវយាយតា ។*

*និយាយពីនគរជម្ពូទ្វីប មានស្តេចសោយរាជ្យមួយអង្គ មានរាជបុត្រី ៩ ពេញវ័យក្រមុំ ។ ថ្ងៃមួយ ព្រះរាជចេញទៅប្រពាតព្រៃហើយ មានតែនាងពៅទេ ដែលទៅលេងតាមព្រះបិតា ។ ពេលនោះ ចៅក្រពតចេញពីស្រោមមកយាមចាំមើលស្រូវហាលនៅមុខផ្ទះ ក៏ក្រឡេកឃើញរាជបុត្រីពៅស្តេច ក៏កើតចិត្តស្រឡាញ់ហើយក្រោយមក ក៏អង្វរឲ្យយាយចាស់ទៅដណ្តឹងបុត្រីទី ៩*(២២) *គឺជាបុត្រីពៅស្តេចនោះ ។ ប្រសិនបើយាយចាស់មិនទៅដណ្តឹងឲ្យទេ ចៅក្រពតថានឹងអត់ដង្ហើមឲ្យស្លាប់ ។ ព្រឹកឡើង យាយចាស់ក៏ចូលទៅបរមរាជវាំង ទូលដណ្តឹងនាងពៅឲ្យចៅក្រពតជាចៅចិញ្ចឹមគាត់ ។ ស្តេចទ្រង់ខ្ញាល់យ៉ាងខ្លាំង ហើយក៏បញ្ជាឲ្យយាយនោះសង់ប្រាសាទមាសប្រាសាទប្រាក់ និងស្ពានមាសស្ពានប្រាក់ ឲ្យបានក្នុងរយៈពេលតែមួយរាត្រី ។ ប្រសិនបើធ្វើមិនបានទេ ព្រះអង្គនឹងយកទៅសម្លាប់ទាំងយាយតា ចៅក្រពត ព្រមទាំងញាតិកាទាំងអស់ ។*

*ព្រឹកថ្ងៃបន្ទាប់ ប្រាសាទមាសប្រាសាទប្រាក់ ព្រមទាំងស្ពានមាសស្ពានប្រាក់ផុសឡើង ដូចបំណាងដោយតេជះទេវតា ។ ស្តេចជម្ពូទ្វីបក៏បង្ខំប្រទ័យព្រមលើកនាងពៅ*(២៣)*ឲ្យចៅក្រពតតាមប្រពៃណី ។ ពេលរាត្រី ចេញពីស្រោមដោយមានរូបឆោមស្រស់បំព្រមមករួមដំណេកជាមួយនាងពៅ រហូតដល់នាងមានផ្ទៃពោះ ជាហេតុឲ្យព្រះបិតាខ្មាសប្រជានុរាស្ត្រ ហាមមិនឲ្យនាងពៅចេញក្រៅវាំង ។ យប់មួយនោះ ពេលស្វាមីនាងដេកលង់លក់ នាងពៅក៏*

---

(២២) តាមអត្ថអក្សរសិល្ប៍សំដីខ្លះ ថា ជារាជបុត្រីពៅទី ៧ ។ É. Porée Maspero, *op. cit.*, p. 442 ។

(២៣) « À la première, il (le roi) demanda si elle voulait épouser un poisson-perroquet ; elle répondit non. La deuxième aussi répondit non, et la troisième aussi, et toutes, sauf la Benjamine (Nāṅ Pou) qui dit :

– Que mon père me marie à un chien, ou à un chat, ou n'importe quel animal, ce sera bien, je ferai sa volonté ». É. Porée-Maspero, *op. cit.*, p. 443 ។

*យកស្រោមក្រពតនោះទៅដុតចោល ហើយផេះនោះក្លាយទៅមាសប្រាក់និងរតនសម្បត្តិផ្សេងៗ ។ ស្ដេចឃើញចៅក្រពតមានរូបឆោមល្អដូចទេវតា ក៏យល់ថាជា អ្នកមានបុណ្យ ។ ព្រះអង្គលើករាជសម្បត្តិឲ្យចៅក្រពតសោយរាជ្យស្នងតទៅ ។»*

*នាងពៅជា «ស្រីគ្រប់លក្ខណ៍»* [២៤] *ហើយចៅក្រពតជាពោធិសត្វ ។*

*សម្រង់ឧទាហរណ៍រឿងព្រេងមួយទៀត* មានចំណងជើងថា **ចៅកង្កែប**[២៥] ៖

*«ស្ដេច ព្រះនាម វិបុលភូមី គ្រងរាជសម្បត្តិក្នុងនគរជ័យបុរី ។ ព្រះមហេសី ព្រះនាម វរត្តទេវី មានបុត្រីមួយព្រះអង្គ ព្រះនាម នាងពៅ ។ ព្រះរាជាសោយរាជ្យប្រកបដោយសុខសន្តិភាព ។*

*ក្នុងនគរនេះ មានតាចាស់យាយចាស់ប្ដីប្រពន្ធក្រីក្រជាទីបំផុត មានតែឈ្នាង ១ និងល្អី ១ ប៉ុណ្ណោះជាសម្បត្តិ ហើយចិញ្ចឹមជីវិតដោយរបរនេសាទត្រី ។ ថ្ងៃមួយ, គាត់ជញ្ជាត់បានកង្កែប ១ ហើយក៏បោះទៅក្នុងទឹកវិញ ហើយក៏ជញ្ជាត់បន្តទៅទៀតជាច្រើនដង បានតែកង្កែបដដែល ។ អ្នកទាំង ២ ក៏ដាច់ចិត្តយកកង្កែបនោះទៅចិញ្ចឹម គឺជាកង្កែបចម្លែកចេះនិយាយភាសាមនុស្ស ។ ថ្ងៃ ១ កង្កែបនោះបានអង្វរយាយចាស់ឲ្យទៅដណ្ដឹងបុត្រីពៅស្ដេច ។ ព្រះរាជាទ្រង់ខ្ញាល់ជាខ្លាំងហើយបញ្ជាឲ្យកង្កែបសង់ស្ពានមាសស្ពានប្រាក់ ពីខ្ទមយាយតារហូតមកដល់ព្រះបរមរាជវាំងក្នុងមួយរាត្រី ។ ប្រសិនបើមិនធ្វើ មិនបានតាមកំណត់ ព្រះអង្គនឹងយកទៅសម្លាប់ចោលទាំងគ្រួសារ ។*

*ដល់ពេលយប់មកដល់ ចៅកង្កែបចេញពីស្រោម ហើយភាវនាបន់ស្រន់ដល់ទេវតា ។ ក្ដៅដល់អាសនៈព្រះឥន្ទ្រាធិរាជ ៗ បើកទិព្វចក្ខុឃើញដូច្នោះ ក៏បញ្ជាឲ្យពិស្ណុការចុះមកសង់ស្ពានមាសស្ពានប្រាក់ ។*

*លុះព្រឹកឡើង, ស្ដេចឃើញស្ពានមាសស្ពានប្រាក់ទាំង ២ នេះ ព្រះអង្គក៏សួរព្រះទ័យបុត្រីពៅជាស្រីគ្រប់លក្ខណ៍ ហើយនាងតបនឹងព្រះអង្គវិញថា ៖*

---

(២៤) សូមអាន រឿង ចៅក្រពត, ទំព័រ ១១ ។

(២៥) ចៅកង្កែប (កែចៅកង្កែប), Paris, Plon-Nourrit, 1901, 26 p. ។

*“បើនឹងឲ្យទៅណា ទោះបីឆ្កែឆ្មាខ្ញុំ ពុំប្រកែកឡើយ”*[២៦] *។ ឮសំដីបុត្រីពោលដូច្នោះ ព្រះរាជាក៏ព្រមរៀបមង្គលការឲ្យបុត្រីទៅចៅកង្កែប ។ នៅពេលផ្សំដំណេក ចៅកង្កែបចេញពីក្នុងស្រោមមករួមដំណេកនឹងនាងពៅ ។ ស្ដេចដឹងការពិតថា ចៅកង្កែបមានរូបឆោមលោមពណ៌ពណ្ណរាយ ជាអ្នកមានបុណ្យ ក៏ទ្រង់លើករាជសម្បត្តិថ្វាយបុត្រប្រសាសោយរាជ្យស្នងព្រះអង្គតទៅ» ។*

*រឿងព្រេងចៅក្រពតនិងចៅកង្កែប ឈរជុំវិញលើចលនានិរន្តរភាព ដូចខាងក្រោមនេះ ៖*

*-តួអង្គឯកកើតក្នុងស្រោមសត្វតិរច្ឆាន,*

*-តួអង្គឯកចង់បានបុត្រីពៅស្ដេចជាភរិយា,*

*-បំពេញកិច្ចការពិបាក គឺត្រូវសង់ស្ពានមាសស្ពានប្រាក់ឲ្យបានក្នុង ១ រាត្រី,*

*-បំពេញកិច្ចការពិបាកបានសម្រេច គឺសង់ស្ពានមាសស្ពានប្រាក់ឲ្យបានក្នុង ១ រាត្រី ដោយអន្តរាគមន៍ទេវៈ,*

*-តួអង្គឯករៀបមង្គលការជាមួយស្រីគ្រប់លក្ខណ៍*[២៧] *ហើយបានឡើងសោយរាជ្យ ។*

## ៤- ស្រីគ្រប់លក្ខណ៍ជាកូនពៅ

*ប្រធានបទ «រៀបការជាមួយកូនស្រីពៅ» មានច្រើននៅក្នុងអក្សរសិល្ប៍ប្រជាប្រិយខ្មែរ ។ តួអង្គដែលបានរៀបការជាមួយបុត្រីពៅស្ដេច ត្រូវបានសោយរាជ្យស្នងព្រះបិតា*[២៨] *។ នាងពៅជា «ស្រីគ្រប់លក្ខណ៍» ត្រូវរៀប*

---

(២៦) ចៅកន្ត្រែត (កែចៅកង្កែប), Paris, Plon-Nourrit, 1901, ទំព័រ ១៧–១៨ ។ សំដីគោរពមាតាបិតាបែបនេះ ដែលនៅក្នុងទំនៀមទម្លាប់ខ្មែរបុរាណ យើងសម្គាល់ថា ជា « ស្រីគ្រប់លក្ខណ៍ » ។

(២៧) សូមអាន V. Propp, *Morphologie du conte*, Paris, Poétique/Seuil, 1970, 254 p. ។

(២៨) តាមប្រពៃណីចាម ទ្រព្យសម្បត្តិស្ដេចចាម ត្រូវបានទៅរាជបុត្រីពៅ ។ សូមអាន É. Porée-Maspero, *op. cit.*, p. 527, n. 6 ។

*ការជាមួយតួអង្គឯក ដែលមានតេជះនិងចំណេះវិជ្ជាខ្ពង់ខ្ពស់លើសមនុស្សធម្មតា ដូចជាតួអង្គពោធិសត្វ ឬជាអ្នកមានបុណ្យ ។ ប្រធានបទនេះមានច្រើនក្នុងរឿងព្រេងនិទានខ្មែរ ឧទាហរណ៍ដូចក្នុងរឿង ៖* **ចៅជីកក្ដាម**, **ចៅភ្លាំងឆាយ**, **ចៅក្រពត**, **ចៅកង្កែប** *។ល។*

*ប្រធានបទ «រៀបការជាមួយកូនស្រីពៅ» មានពណ៌នាក្នុង* **រឿងរាជកុល**(២៩) *ដែលតាក់តែងឡើង ដោយវរបញ្ញាក្នុងរវាងសតវត្សទី ១៨ និងទី ១៩ ។*

*ក្នុងនគរមួយនោះ សោយរាជ្យដោយស្ដេចមួយព្រះអង្គ ព្រះនាម ព្រះចន្ទរាជ មានព្រះមហេសី ព្រះនាម ចន្ទទេវី ។ ព្រះអង្គមានបុត្រី ៣ ព្រះអង្គ ។ បុត្រីបងបង្អស់ ព្រះនាម រាជទេវី ឯបុត្រីប្អូនបង្អស់ ព្រះនាម នាងពៅ មានរូបឆោមល្អឥតគណនា គឺជា «ស្រីគ្រប់លក្ខណ៍»*(៣០) *។*

*ក្នុងនគរនោះ មានតាចាស់យាយចាស់ប្ដីប្រពន្ធ ។ តា នាម ទូកី ហើយយាយ នាម មីងទុរគតកុមារី, អ្នកទាំងពីររស់នៅក្នុងក្ដីតោកយ៉ាក ហើយឥតមានបុត្រធីតាសោះឡើយ ។ គាត់មានចិត្តសទ្ធាជ្រះថ្លា ចង់ធ្វើទាន តែគាត់មានប្រាក់តែមួយស្លឹង*(៣១) *ប៉ុណ្ណោះ ។ តាចាស់និយាយទៅកាន់យាយជាប្រពន្ធថា "យើងយកប្រាក់នេះទៅទិញនង្គ័លរនាស់និងពូជស្រូវ ហើយយើងនឹងធ្វើស្រែ ។ ពេលណាយើងបានភោគផល យើងមានប្រាក់អាចយកទៅធ្វើទានបាន ។" តាំងពីពេលនោះមក តាចាស់យាយចាស់ចាប់ខំធ្វើស្រែ ដោយឥតសំចៃកម្លាំង ។ ស្រែគាត់ដុសឡើងខៀវស្រងាត់ គាត់មកចាំយាមស្រែគាត់ដោយយកចិត្តទុកដាក់បំផុត រៀងរាល់ថ្ងៃ ធ្វើឲ្យក្ដៅដល់អាសនៈព្រះឥន្ទ្រ ៗ បើកទិព្វចក្ខុឃើញដូច្នោះ ក៏ទៅសុំរាជកុលជាបុត្រទេវរាជតួអង្គពោធិសត្វ ឲ្យ*

---

(២៩) សាស្ត្រាស្លឹករឹត តម្កល់នៅបណ្ណាល័យសាលាបារាំងចុងបូព៌ា ចុះលេខ ៨៨, ៨ ខ្សែ ។ សូមអាន J. Guesdon, « Reach kol, analyse et critique du poème khmêr », *Anthropos* I (1906), p. 804–816 ។

(៣០) សាស្ត្រាស្លឹករឹត តម្កល់នៅបណ្ណាល័យសាលាបារាំងចុងបូព៌ា ចុះលេខ ៨៨, ខ្សែ ១, សន្លឹក « ខ » (លក្ខណា...) ។

(៣១) ស្លឹងជាប្រាក់បុរាណមានរូបក្ដាម ។

*ចុះទៅស្ថានកណ្ដាលជួយតាចាស់យាយចាស់ ដែលក្រីក្រលំបាក ។ រាជកុល ដោយយល់ថា ព្រះអង្គជាគូពីអតីតជាតិនឹងនាងពៅបុត្រីស្ដេចព្រះចន្ទរាជ ក៏ចុះទៅតាមនាង នៅឋានកណ្ដាល ។*

*រាជកុលលាព្រះមាតាបិតាចូលទៅក្នុងស្រោមសេះស ចុះដល់ស្រែតាចាស់យាយចាស់ ហើយស៊ីសំណាបតាយាយនោះ ។ តាទូភីចាប់សេះនោះហើយនាំមកផ្ទះ ។*

*ស្ដេចដឹងថា តាចាស់យាយចាស់នោះ មានសេះសល្អប្រសើរ ក៏បញ្ជាឲ្យនាម៉ឺនមន្ត្រីទៅនាំសេះសនោះ ព្រមទាំងតាយាយទាំងពីរមកផង ហើយព្រះរាជាបានផ្ដល់រង្វាន់ជាច្រើន មានប្រាក់កាស ជាដើម ឲ្យជនកំសត់ទាំងពីរប្រាណនោះ ។ ដោយផលានិសង្ស តាយាយទាំងពីរក៏ក្លាយរូបកាយជាក្មេង ។*

*ព្រះចន្ទរាជស្រឡាញ់ឥតឧបមាសេះសនោះៗ ក៏មានចិត្តប្រតិព័ទ្ធលើនាងពៅបុត្រីស្ដេច ។ ថ្ងៃមួយ សេះសនោះថ្ងូរយ៉ាំងខ្លាំង ធ្វើឲ្យព្រះរាជាព្រួយព្រះទ័យ ក៏ហៅហោរាមកឲ្យទស្សន៍ទាយ ហើយហោរានោះទូលស្ដេចវិញថា សេះសនោះចង់រៀបការជាមួយបុត្រីព្រះអង្គ ។ ស្ដេចសួរយោបល់ព្រះនាងទី ១ ៗ ប្រកែកហើយព្រះនាងទី ២ ក៏ប្រកែកទៀត ។ តែដល់នាងពៅ ៗ ក៏យល់ព្រមទទួលហើយពោលពាក្យថា ៖*

«ច្បាប់ស្រ្សីពិត្តព្យ៍បូរ៉ា តាមតែរមេតា
លោកតាកតាំមហោង ។
ទៀវទូជស្រមោចក្ដាមខ្យង សារពើរសត្វផង
ខ្ញំមតៀព្ញំខាន្ទ ។» *(អក្ខរាវិរុទ្ធដើមក្នុងសាស្ត្រា)* (៣២) ។

---

(៣២) សាស្ត្រាស្លឹករឹត តម្កល់នៅបណ្ណាល័យសាលាបារាំងចុងបូព៌ា ចុះលេខ ៨៨, ខ្សែ ២, សន្លឹក « ក » ។ កែតាមអក្ខរាវិរុទ្ធទំនើប ៖

« ច្បាប់ស្រីពិតពីបូរាណ៍ តាមតែមេបា
លោកដាក់ដាំហោង ។
ទៀវទូចស្រមោចក្ដាមខ្យង សារពើសត្វផង
ខ្ញុំដោយពុំខាន ។»

*ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយសេះសពោធិសត្វ, នាងពៅបំពេញកិច្ចការទាំងថ្ងៃយប់ជាភរិយា «ស្រីគ្រប់លក្ខណ៍» ចំពោះប្ដីជាសត្វសេះស ។ ពេលរាត្រីមកដល់ រាជកុលបានចេញពីស្រោមសេះ មានរូបកាយល្អឥតផ្ទឹម មករួមរ័ក្សជាមួយនាងពៅ ។ ក្រោយមក ស្ដេចចន្ទរាជបានដឹងថា រាជកុលជាអ្នកមានបុណ្យ ក៏ផ្ទេររាជសម្បត្តិឲ្យសោយរាជ្យស្នងព្រះអង្គតទៅ ។*

*តាមទំនៀមបូរាណ នាងពៅជាបុត្រីល្អឥតខ្ចោះក្នុងគ្រួសារ ។ នាងពៅរមែងគោរពនិងស្ដាប់បង្គាប់មាតាបិតាជានិច្ចជាកាល ។ ក្នុងអក្សរសិល្ប៍ទំនៀម នាងពៅជាស្រី មានលក្ខណៈសម្បត្តិប្រសើរ និងមានរូបសម្បត្តិល្អប្រិមប្រិយ ពោលគឺជា «ស្រីគ្រប់លក្ខណ៍» ។ នាងពៅជាទីស្រឡាញ់ពេញចិត្តរបស់គ្រួសារ ដែលផ្ទុយនឹងនាងបងបង្អស់ ដែលរមែងមានទំនាស់ទំនុយនឹងអំណាចមាតាបិតា ។*

## ៥– « ស្រីគ្រប់លក្ខណ៍ » ៖ ភរិយាស្រីសួគ៌

*ក្នុងសាស្ត្រាល្បែងជាទូទៅ តួអង្គស្ត្រី គឺជា «ស្រីគ្រប់លក្ខណ៍» ដែលជាស្រីសួគ៌ច្យុតិយោនកំណើតមកស្ថានកណ្ដាល ជាគន្ស្រសពេជ្ជពោធិសត្វ ។ យើងលើកឧទាហរណ៍សាស្ត្រាល្បែង ១ គឺ* **រឿងភោគកុលកុមារ** *គឺតួអង្គឯកស្ត្រីជា «ស្រីគ្រប់លក្ខណ៍» និងជាស្រីសួគ៌ ។*

*«ព្រះឥន្ទ្រសុំឲ្យទេពធីតាចុះពីវិមានអាកាស មកជួបនឹងពោធិសត្វជាស្វាមី (...) ៖ ដោយបុណ្យបារមី ភោគកុមារជាពង្សពេជ្ជ ធ្វើឲ្យក្ដៅដល់អាសនៈព្រះឥន្ទ្រាធិរាជ ។ ក៏បើកទិព្វចក្ខុ ហើយឃើញថា ភោគកុលកុមារមិនទាន់មានគូវាសនានៅឡើយ ។ ព្រះសក្កទេវរាជបានសុំឲ្យទេពធីតានេះច្យុតិចុះមកនគរសត្តកុដបុរី ក្នុងឧទរព្រះអគ្គមហេសីស្ដេចសត្តកុដរាជ ។ រាជបុត្រីនេះចម្រើនវ័យបាន ១៦ វស្សា ហើយមានរូបសម្បត្តិល្អឥតផ្ទឹម ដូចស្រីសួគ៌ គឺជាស្រីគ្រប់លក្ខណ៍, បន្ទាប់មក បានភោគកុលកុមារជាព្រះភស្ដា ។*(៣៣) »

---

(៣៣) Cf. Khing Hoc Dy, *Un auteur cambodgien et son œuvre : le Bhogakula-kumār du poète Naṅ (fin 18ème–début 19ème siècle)*, Phnom Penh, Éditions Angkor, 2006, 334 p. ។

*អ្នកស្រី ប៉ូរេ-ម៉ាស្ពេរ៉ូ បានកត់ត្រាអក្សរសិល្ប៍សំដីមួយ មានចំណងជើងថា «* **ព្រះសុធន** *»*[៣៤]*, រាជកុមារនេះមានកិរិយាជាស្រីសួគ៌ ។ អត្ថបទសំដីនេះទៀតសោត ក៏មានជាសាស្ត្រាស្លឹករឹត*[៣៥] *ហើយរឿងនេះមាននៅក្នុងបញ្ញាសជាតកបាលី*[៣៦] *តែមានលក្ខណៈខុសគ្នាច្រើនដែរ ។*

*ក្នុងអត្ថបទសាស្ត្រាព្រះសុធន, នាងមនោហរា រាជបុត្រីពៅស្តេចទេវតាជា «ស្រីគ្រប់លក្ខណ៍» ដូចមានសេចក្តីបញ្ជាក់ស្រាប់ ៖*

«ព្រះពង្សពោធិសត្វ បុរសរ័ត្នរាជភូមី
ចុះចាកយានហត្ថី ឡើងទៅគង់ព្រះពន្លា ។
ហើយស្តេចចរចូលទៅ ដល់ប្អូនពៅស្រីសួគ៌
នាងយល់ព្រះរាជា ចូលទៅដល់មណ្ឌលទី ។ (...)
នាងខ្មាសពុំមៀងមើល ក្សត្រប្រសើរទូលថា
ប្អូនមាសមាស**លក្ខណា** នាងនឹងបាននេះហេតុបុណ្យ ។[៣៧]»

*សេចក្តីសង្ខេបរឿងព្រះសុធន ៖*

*«ព្រះបាទអាទិត្យរាជសោយរាជ្យសម្បត្តិនៅនគរបញ្ចាល ។ ព្រះអង្គអគ្គមហេសី ព្រះនាម នាងចន្ទាទេវី និងស្រីស្នំជាច្រើន តែគ្មានព្រះរាជបុត្រ ។*

*ដោយពិធីបួងសួងសុំរាជបុត្រ, ថ្ងៃមួយ មានទេវបុត្រមួយព្រះអង្គច្យុតមកចាប់បដិសន្ធិក្នុងព្រះឧទរព្រះនាងចន្ទទេវីជាព្រះអគ្គមហេសី ។ ព្រះនាងប្រសូតបានរាជបុត្រមួយព្រះអង្គ ប្រកបដោយរូបឆោមលោមពណ៌ល្អឥតឧបមា ។ ស្តេចទ្រង់ប្រជុំអស់នាម៉ឺនមុខមន្ត្រីកវីបណ្ឌិតបុរោហិតទាំងអស់ដើម្បីថ្វាយព្រះនាមដល់រាជកុមារថា «សុធនកុមារ» ។ លុះព្រះសុធនកុមារចម្រើនវ័យបាន ១៦ ព្រះវស្សា ព្រះវរបិតាបញ្ជាឲ្យស្តេចចំណុះទាំង ១០១*

(៣៤) É. Porée-Maspero, *op. cit.*, p. 657–658 ។

(៣៥) ព្រះសុធន, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៣, ១៤៤ ទំព័រ ។

(៣៦) ញ៉ុក ថែម, *បញ្ញាសជាតកសង្ខេប*, ភ្នំពេញ, មហាវិទ្យាល័យអក្សរសាស្ត្រ, ១៩៦៣, ទំព័រ ៥០–៧០ ។

(៣៧) ព្រះសុធន, ទំព័រ ៣០ ។

យកបុត្រីមកឲ្យរាជបុត្ររើសជាព្រះអគ្គមហេសី ។ តែបណ្ដាព្រះរាជធីតាទាំងនោះ គ្មាននាងណាមួយធ្វើឲ្យព្រះសុធនពេញព្រះហឫទ័យឡើយ ។

ក្រោយពីរាជធីតាស្ដេចចំណុះ ១០១ ត្រឡប់ចូលនគរវិញរៀងៗខ្លួន, តារាជបុរោហិតយកកូនស្រីរបស់ខ្លួន នាម នាងឯកាណំ មកថ្វាយព្រះសុធនកុមារទុកជាព្រះស្នំ ។

និយាយពីនៅក្នុងនគរបញ្ចាលនោះ មានព្រានព្រៃម្នាក់ឈ្មោះ បុណ្ឌរិក តែងរង្គាត់តាមព្រៃ ដើម្បីបរបាញ់ម្រឹគយកទៅលក់ចិញ្ចឹមជីវិត ។ ព្រាននេះបានទៅប្រទះស្រះស្រង់មួយកណ្ដាលព្រៃហិមពាន្ត ។ ស្រះស្រង់នេះជាទីកំសាន្តនៃហ្វូងកិន្នរី ដែលរមែងហោះចុះពីឋានកៃលាស មកងូតទឹកលេងសប្បាយ ។ ស្ដេចកិន្នរនាឋានកៃលាសនោះ ទ្រង់ព្រះនាម ព្រះបាទឧទម្ពរ ព្រះអង្គមានរាជបុត្រី ៧ ព្រះអង្គ ហើយនាងពៅមានរូបឆោមល្អដាច់គេ ព្រះនាម «មនោហរា» ។

នាពេលមួយនោះ ព្រះអគ្គមហេសីព្រះបាទឧទម្ពរ ទ្រង់ព្រះសុបិនថាមានមនុស្សម្នាក់ខ្មៅអាក្រក់គួរខ្លាច យកដាវមកកាត់ព្រះសិរ ហើយពុះទ្រូងរូងយកថ្លើមព្រះនាងចេញទៅ ។ ព្រឹកឡើង ព្រះនាងបានទូលព្រះស្វាមីពីសុបិនអាក្រក់នេះ ដល់ព្រះស្វាមីៗទ្រង់បញ្ជាឲ្យហៅហោរមកគន់គូរមើលពីសុបិនចំឡែកនេះ ។ ហោរបានទាយថា លទ្ធផលអាក្រក់នឹងត្រូវធ្លាក់ទៅលើរូបព្រះនាងមនោហរាៗ នឹងត្រូវព្រាត់ប្រាស់ចេញពីព្រះមាតាបិតា ដោយប្រការណាមួយមិនខាន ។ ចាប់ពីពេលនោះមក ព្រះបាទឧទម្ពរហាមផ្ដាច់មិនឲ្យបុត្រីទាំងអស់ហោះទៅកំសាន្តទីណាដូចមុនៗឡើយ ។

និយាយពីនគរបញ្ចាល ព្រានបុណ្ឌរិកតែងតែទៅបរបាញ់សត្វរៀងរាល់ថ្ងៃក្នុងព្រៃហិមពាន្តក្បែរៗស្រះស្រង់នោះ ។ ថៃ្ងនៃ្យអី ថ្ងៃនោះ មានគ្រុឌមួយហើរកាត់ពីលើស្រះ ក្រឡេកមកក្រោម ឃើញនាគរាជមួយកំពុងហែលទឹកលេង ក៏ហោះចុះឆាបឆក់នាគមួយ ហោះឡើងលើវាហាស៍ ដើម្បីយកជាចំណី ។ ពេលនោះ ព្រានបុណ្ឌរិកឃើញដូច្នោះ ក៏យឹតធ្នូបាញ់ត្រូវបក្សី ។ គ្រុឌឈឺពេក ក៏ទម្លាក់នាគចោល ។ នាគសប្បាយចិត្ត ដោយរួចជីវិត ក៏និយាយនឹងព្រានថា បំណងចាប់កិន្នរីមួយដែលមានរូបឆោមលោមពណ៌ល្អ

ជូន ដើម្បីសងគុណដ៏ធ្ងន់នេះ ហើយប្រាប់ព្រានថា កុំឲ្យទៅណាឆ្ងាយ បើឮសូរមាត់ស្រែកឲ្យរត់មកជាប្រញាប់ ។

ថ្ងៃងពីនាងមនោហរាជាធីតាពៅស្តេចឧទមកពរ ថ្ងៃនោះ អផ្សុកពេកអង្វរឲ្យបង ៗ ស្រីទាំង ៦ នាក់ជូននាងទៅកំសាន្ត នៅស្រះស្រង់ នាព្រៃហិមពាន្ត ។ ពេលដែលនាងទាំង ៧ ងូតទឹកលេងសប្បាយ នាគហែលសន្សឹម ៗ ទៅវ័ណ្ឌដើងនាងមនោហរារឹតជាប់ មិនឲ្យរើទៅណាបាន ។ នាងស្រែកខ្លាំង ឮទៅដល់ព្រានព្រៃ ៗនោះរត់មកយកស្វាបលាក់ទុកឲ្យហើយ រួចស្រែកប្រាប់នាគថា ឲ្យលែងនាងចុះ ។ ព្រានបុណ្ឌរិកយកនាងមនោហរាជាស្រីសួគ៌និងជាស្រីគ្រប់លក្ខណ៍ ទៅថ្វាយព្រះសុធនកុមារ ៗ ក៏តាំងព្រះនាងជាព្រះអគ្គមហេសី ជាហេតុនាំឲ្យនាងឯកណំខឹងច្រណែន ។

ស្ដេះនិយាយពីនគរបញ្ចាល ជានគរចំណុះ សោយរាជ្យដោយស្តេច ព្រះនាម ព្រះបាទនន្ទរាជ ៗ បែរព្រះទ័យចង់បង្កសង្គ្រាមតបតនឹងស្តេចអាទិត្យរាជវិញ ដោយពុំព្រមនាំអាករមកថ្វាយ ។ ព្រះបាទអាទិត្យរាជបញ្ជាឲ្យព្រះសុធនកុមារជាព្រះរាជបុត្រ ចេញទៅធ្វើសឹកបង្ក្រាបស្តេចនន្ទរាជ ៗ ទ្រង់ភិតភ័យសុំចុះចាញ់ព្រះសុធនកុមារ ។

នៅពេលដែលព្រះសុធនលើកពលរេហ៍ទៅច្បាំង ព្រះបាទអាទិត្យរាជទ្រង់សុបិនឃើញខ្មាំងចាក់ព្រះរាជបុត្រ ត្រូវពោះឈាមហូរធ្លាក់ចុះពាសពេញ ។ លុះភ្ញាក់ឡើង ស្តេចទ្រង់បញ្ជាឲ្យហៅហោរមកគន់គូរពីសុបិនចំឡែកនេះ ។ ឯហោរនោះ ជាបិតានាងស្នំឯកណំ ដែលមានគម្រោងនិងឧបាយកលចង់ឲ្យកូនស្រីខ្លួនជាអគ្គមហេសីព្រះសុធនកុមារ ក៏ទាយបង្វែងដានថា ព្រះសុបិននេះជាបុព្វនិមិត្តនៃសេចក្តីវិនាស ដល់ព្រះអង្គនិងដល់ប្រជារាស្ត្រទាំងអស់ ។ ដើម្បីបញ្ចៀសមហន្តរាយនេះ ត្រូវធ្វើពិធីបូជាយញ្ញដុតសត្វទាំងរស់ហើយពពួកសត្វទាំងនោះ គឺមាននាងមនោហរាផងដែរ ទើបអាចលុបលាងកំហឹងទេវតាបាន ។ ព្រះអាទិត្យរាជក៏យល់ព្រមធ្វើតាមយោបល់តាហោរ ។

ពេលនោះ នាងមនោហរាគិតរកឧបាយដោះខ្លួនឲ្យរួចពីស្លាប់ គឺនាងចង់ហោះរំដោះខ្លួន តែគេបានយកស្លាបនាងរក្សាទុកមួយកន្លែង ។ នាងក្រាបទូលព្រះបាទអាទិត្យរាជថា មុននឹងស្លាប់ នាងសុំរាំថ្វាយកំសាន្តព្រះហឫទ័យ

ព្រោះតាំងពីពេលដែលនាងមកធ្វើជាព្រះសុណិសា នាងមិនដែលបានរាំថ្វាយព្រះអង្គទតម្តងសោះ ។ នាងមនោហរារាំចាក់ក្បាច់លូតលូន់ ធ្វើឲ្យទស្សនិកជនពោមមើលភ្លេចខ្លួនព្រមទាំងតាហោរ ហើយនាំគ្នាទះដៃកោតសរសើរផង ។ ដោយយល់ថាមហាជនពេញចិត្តហើយ នាងក៏សុំស្លាបមកពាក់ដើម្បីឲ្យពេញលក្ខណៈដារបាំនៅឋានកៃលាស ។ នាងបានស្លាបមកពាក់រាំថ្វាយបិតាហើយក៏ស្ទុះហោះរត់ទៅ ។

ដល់អាស្រមឥសីក្នុងព្រៃហេមពាន្ត នាងចុះទៅថ្វាយបង្គំតាបស ហើយដោះព្រះទម្រង់និងកន្សែងមួយផ្ញើទុកនឹងលោកតាឥសី ក្រែងព្រះសុធនជាស្វាមីមកតាម ហើយផ្តាំសុំឲ្យលោកតាមេត្តាប្រគល់ទាំងនេះថ្វាយព្រះស្វាមីផង ។ មុននឹងលាតាឥសី នាងបានផ្ញើទុកសម្រាប់ព្រះសុធននូវកូនតម្រាមួយជាមគ្គុទ្ទេសក៍នាំផ្លូវទៅឋានកៃលាស ព្រមទាំងថ្នាំគុលិកាសម្រាប់ការពារខ្លួន ។ ផ្តាំហើយ នាងក៏ហោះទៅកាន់ឋានកៃលាស ។

ព្រះបាទឧទម្ពរ, ព្រះអគ្គមហេសី, រាជបុត្រីនាងកិន្នរីទាំង ៦ ព្រមទាំងបរិពារ មានសេចក្តីត្រេកអរឥតឧបមា ។ ព្រះរាជាទ្រង់បញ្ជាឲ្យទេវតាជាបរិវាររៀបចំធ្វើពិធី ស្រង់ទឹក កក់ព្រះកេសា នឹងជំរះកាយឲ្យនាងមនោហរា ។ ពិធីនេះត្រូវប្រារព្ធធ្វើអស់រយៈពេល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។

ស្វែះសិនថ្លែងពីព្រះសុធនកុមារវិញ ។ ស្តេចទ្រង់ត្រឡប់មកនគរបន្ទាប់ពីបានជោគជ័យលើស្តេចនន្ទរាជ ទ្រង់សុំញ៉មចំណុះចុះចូលមកវិញ ។ មកដល់ព្រះនគរព្រះសុធនជ្រាបដំណឹងអាក្រក់ ក៏បង្គំលាព្រះបិតាមាតា ទៅតាមព្រះមហេសីមនោហរា ដោយយកព្រានព្រៃបុណ្ឌរិកជាអ្នកនាំផ្លូវ ។ អ្នកទាំងពីរបានទៅដល់អាស្រមមហាឥសី ៗ ប្រាប់ដំណឹងសព្វគ្រប់ស្តីពីបណ្តាំនាងមនោហរា ហើយប្រគល់វត្ថុនានាដែលនាងផ្ញើទុកឲ្យស្វាមី ។ ព្រះសុធនទ្រង់បញ្ជូនបុណ្ឌរិកឲ្យនាំអស្សតរត្រឡប់ទៅនគរវិញ ហើយផ្តាំឲ្យព្រះបិតាចាប់តាហោរឬស្យាដាក់ទ្រុងដេកទុកចាំព្រះអង្គត្រឡប់ចូលរាជបុរីវិញ ។ ព្រះសុធនធ្វើដំណើរទៅទៀតអស់រយៈពេល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបបានទៅដល់ឋានកៃលាស ដោយសុំដោយសារនឹងសត្វឥន្ទ្រី ។

*នៅជិតស្រះស្រង់ ឃើញបរិពារមកដងទឹកយកស្រង់ឲ្យនាងមនោហរា, ព្រះសុធនក៏សូត្រមន្តវិជ្ជាធ្វើជាទម្ងន់ ដែលបរិពារទាំងនោះលើកមិនរួច ហើយព្រះអង្គមកជួយលើករួច ក៏ធ្មៀតដាក់ចិញ្ចៀនព្រះទម្រង់ក្នុងក្អមទឹក ។ ពេលនាងមនោហរាស្រង់ទឹកជ្រងព្រះកេសា, ព្រះទម្រង់ចូលក្នុងម្រាមដៃនាង ដូចជាគេបំពាក់ឲ្យ ។ នាងយល់ភ្លាមថា ព្រះស្វាមីមកតាមនាង ៗ ក៏ទូលព្រះបិតាតាមដំណើរ ។ ស្ដេចឧទម្ពរល្បងឲ្យព្រះសុធនលើផ្ចង់ជ័យ ។ ដោយឃើញព្រះរាជសុណិសាមានរិទ្ធិចេស្ដាខ្លាំង គ្មានអ្នកណាប្រៀបបាន ក៏រៀបពិធីអភិសេកព្រះសុធននឹងនាងមនោហរា ក្រោមអធិបតីភាពព្រះឥសូរ ។ យូរបន្តិចមកព្រះសុធននិងព្រះជាយាត្រឡប់មកបញ្ចារាជធានីបិញ ។ តមក នាងមនោហរាប្រសូតបានព្រះរាជបុត្រមួយព្រះអង្គ មានព្រះនាមថា ចៅបទុមវង្ស ៗ ចម្រើនវ័យឡើង ទ្រង់រៀបការនឹងនាងសុវណ្ណមាលារត្ន ជាបុត្រីនៃព្រះបាទនន្ទរាជ ហើយឡើងសោយរាជ្យស្នងព្រះសុធនកុមារជាបិតា ។ ព្រះសុធនទ្រង់ចេញទៅបួសជាតាបសនាព្រៃហេមពាន្ត ដើម្បីបំពេញបារមីនឹងបានត្រាស់ជាពុទ្ធអង្គនាអនាគតកាល ។*

*ទីបញ្ចប់មានការសរជាតិ ។»*

## **៦– ការស្វែងរកស្រីគ្រប់លក្ខណ៍**

*ប្រធានបទ «ការស្វែងរក» មានពាសពេញក្នុងអត្ថបទអក្សរសិល្ប៍ប្រជាប្រិយខ្មែរ*(៣៨) *និងអក្សរសិល្ប៍ប្រជាប្រិយជាទូទៅ*(៣៩) *ពោលគឺជាប្រធានបទសកល ។ នៅពេលណាមាន «ការខ្វះ» គឺមាន «ការស្វែងរក» ។ «កង្វះ»*

(៣៨) សូមអាន Solange Thierry, *Le Cambodge des contes*, Paris, L’Harmattan, 1985, 295 p. ។

(៣៩) សូមអាន Vladimir Propp, *Morphologie du conte*, Paris, Poétique/Seuil, 1970, 254 p. ។

ស្រីគ្រប់លក្ខណ៍[៤០] មានពណ៌នាជាឧទាហរណ៍ក្នុងរឿងព្រេងនិទាន « **ស្រីពិត ម្ដាយពិត ឪពុកពិត** »[៤១] ៖

« បុរសម្នាក់ជាក្មេងកំព្រាកំសត់ទុគ៌តក្រលំបាក មានបំណងចង់ដឹងថា នៅក្នុងនគរនោះ មានស្រីពិត, ម្ដាយពិត, ឪពុកពិតឬទេ? បុរសនោះចាប់ផ្ដើមដើររកគ្រួសារពិតក្នុងនគរនោះ ។

ថ្ងៃមួយ, ព្រះរាជាស្ដេចទ្រង់បង្គាប់ឲ្យនាហ្មឺនមុខមន្ត្រីធំម្នាក់ចេញទៅធ្វើពេងសង់សាលាបុណ្យ នៅត្រើយម្ខាងស្ទឹងហើយស្ទឹងនោះមានស្ពានមួយស្ទួង ។ បុរសក្រកំសត់នោះអង្គុយស្ទូចត្រីនៅក្រោមស្ពាននោះ ។ ស្ដេចទ្រង់យាងទៅសាលាបុណ្យមុន, ហើយដល់ពេលរសៀល ព្រះរាជបុត្រីពៅរៀបព្រះកាយចេញទៅបុណ្យក្រោយ ។ ពួកស្រីស្នំក្រុមការឆ្លងស្ពានហួសអស់ទៅ នៅតែព្រះនាង មិនព្រមយាងឆ្លងស្ពានលើក្បាលបុរសកំសត់នោះ[៤២] ។ ទើបព្រះនាងពៅស្រដីទៅកាន់បុរសកំសត់ឲ្យចេញពីក្រោមស្ពាន ទើបព្រះនាងពៅសុខព្រះទ័យឆ្លងស្ពាននោះ ទៅកន្លែងបុណ្យជាមួយព្រះបិតា ។ ឃើញដូច្នោះ បុរសកំសត់យល់ថា ព្រះនាងពៅគឺជា “ស្រីគ្រប់លក្ខណ៍” ។

នៅក្នុងពិធីបុណ្យនោះ ចៅបុរសកំសត់ជាអ្នកស្វះស្វែងចង់ចូលគាល់ព្រះរាជា ។ នាយទាហានចាំទ្វារ ឃើញបុរសកំសត់នោះមានសំលៀកបំពាក់ដាច់ដាច ក៏ឃាត់មិនឲ្យចូល ។ បុរសនោះនិយាយខ្លាំងៗ ដើម្បីឲ្យស្ដេចឮ ហើយព្រះរាជាអនុញ្ញាតឲ្យចូលគាល់ ហើយសួរថា «ចៅបុរសឯងនិយាយថា ក្នុងនគរអញនេះ គ្មានស្ត្រីពិត ម្ដាយពិត ឪពុកពិត ទេ តើចៅបុរសឯងថាដូច្នោះមែនឬដូចម្ដេច?» ។ ចៅកំសត់ក្រាបទូលវិញថា “សូមទ្រង់មេត្តាប្រោស ក្នុងទីព្រះនគររបស់ល្អងធូលីព្រះបាទនេះ គ្មានស្ត្រីពិតម្ដាយពិតឪពុកពិតទេ ទូល

(៤០) តាម Vladimir Propp « កង្វះ » តំណាងដោយអក្សរ **a1** ។

(៤១) *ប្រជុំរឿងព្រេងខ្មែរ*, ភាគ ២, បោះពុម្ពលើកទី ៥, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨, ទំព័រ ១១១-១២៨ ។ រឿងនេះបោះពុម្ពនៅប្រទេសបារាំងដំបូង ដោយ J. Guesdon, **រឿងស្រីពិតម្ដាយពិតឪពុកពិត**, Paris, Plon-Nourrit, 1902, 25 p. ។

(៤២) តាមទំនៀមបុរាណ ទំនាក់ទំនងប្រុសនឹងស្រី គឺមិនឲ្យស្រីដើររំលងក្បាលបុរស ឬក៏កាន់ក្បាលបុរសឡើយ ។ សូមអាន S. Thierry (1976), *op. cit.*, p. 329, n. 1 ។

*ព្រះបន្ទំជាខ្ញុំថាមែន, ម្ដាយពិតឪពុកពិតគ្មាន ជាខ្ញុំថាមែន” ។* (...) *“សូមទ្រង់មេត្តាប្រោស ឯស្រីពិតមានតែមួយ ដែលជាព្រះរាជបុត្រីពៅព្រះករុណាពិសេសនេះ ទើបហៅស្រ្តីកបនរល័ក្ខណ៍ជាក់ជាស្រ្តីពិតមែន” ។ ស្ដេចយល់ដូចបុរសកំសត់ថ្លៃងមែន ហើយព្រះអង្គទ្រង់មានព្រះទ័យចង់ស្វះស្វែងរក “ស្រ្តីពិត, ម្ដាយពិត, ឪពុកពិត” នៅក្រៅព្រះនគរ ។ ព្រះអង្គទ្រង់ប្រទានរង្វាន់ជាមាសប្រាក់សំពត់អាវឲ្យបុរសកំសត់ ហើយព្រះអង្គទ្រង់ក្លែងព្រះកាយជាអ្នកក្រខ្សត់ទុគ៌តចេញពីបរមរាជវាំង ។*

*ដំបូង ស្ដេចបានជួបនឹងគ្រួសារទី ១ ហើយព្រះអង្គសាកល្បងនឹងគ្រួសារនេះ តែទ្រង់យល់ថាមិនមែន “គ្រួសារពិត” ទេ ក៏ធ្វើដំណើរតទៅទៀត ហើយបានជួបសំណាក់នឹងយាយតាប្ដីប្រពន្ធ ។ ស្ដេចទ្រង់ឲ្យតាយាយទៅដណ្ដឹងកូនក្រមុំមានកិរិយាមាយ៉ាទល្អជា “ស្រ្តីគ្រប់លក្ខណ៍” ហើយបានរៀបការតាមប្រពៃណី ។ ថ្ងៃមួយ ព្រះអង្គបានសាកល្បងមាតាបិតាក្មេកសម្រេចដូចបំណង យល់ថា ជា “គ្រួសារពិត” ។ ព្រះអង្គសព្វព្រះទ័យ ក៏នាំប្រពន្ធជា “ស្រ្តីគ្រប់លក្ខណ៍” ចូលបរមរាជវាំងវិញ* (៤៣) *។»*

*ការស្វះស្វែងរក «ស្រីគ្រប់លក្ខណ៍» នេះ មានក្នុងអត្ថបទអក្សរសិល្ប៍ខ្មែរជាច្រើនទៀត ដូចជា ក្នុងរឿង* **ធនញ្ជ័យ** *ឬ* **ធ្មេញជៃ** (៤៤) *ជារឿងព្រេងមួយដែលមានប្រជាប្រិយភាពជាខ្លាំងទូទាំងប្រទេសកម្ពុជាទាំងមូល ។ តួអង្គឯកគឺជាអ្នកប្រាជ្ញធំខ្មែរម្នាក់ ដែលអាចដោះប្រស្នាជាមួយអ្នកប្រាជ្ញចិន បានឈ្នះ ហើយចិនត្រូវខាតបង់របស់ទ្រព្យជាច្រើនសំពៅ ដោយចាញ់ប្រាជ្ញាកលល្បិចធនញ្ជ័យ ហើយធនញ្ជ័យប្រគល់ទ្រព្យសម្បត្តិទាំងនេះ ទៅព្រះមហាក្សត្រ ៗ ត្រេកអរហើយឲ្យធនញ្ជ័យរើសស្រីក្នុងរាជវាំងនេះធ្វើជាប្រពន្ធ ។ តែធនញ្ជ័យទូលស្ដេចវិញថា ស្រីទាំងនេះមិនមែន «ស្រ្តី» ទេ គឺសុទ្ធតែជា «ញី» ។*

---

(៤៣) ការសិក្សាលំអិតរឿងព្រេងនេះ សូមអាននិក្ខេបបទថ្នាក់បណ្ឌិតរដ្ឋសាស្ត្រាចារ្យ S. Thierry (1976), *op. cit.*, p. 327–336 ។

(៤៤) ធនញ្ជ័យ, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៤, ៦២ ទំព័រ ។ រឿងនេះ បកប្រែជាភាសាបារាំងដោយ P. Bitard sous le titre de « La merveilleuse histoire de Thmenh Chey, l’astucieux », *France-Asie* (1956), n° 116–117 et 121–122, 48 p. ; É. Aymonier, *op. cit.*, p. 20–30 et 67–115 ។

*ហេតុនេះ ធនញ្ជ័យមានបំណងចង់បានប្រពន្ធជា «ស្រីពិត» ក៏សម្រេចចិត្តចេញពីរាជវាំង ដើម្បីទៅធ្វើ «ការស្វែងរកស្រីពិត» ដែលជា «ស្រីគ្រប់លក្ខណ៍» គឺជាស្រីប្រកបដោយ «សួស្តី»* [៤៥] *។ ធនញ្ជ័យស្វែងរកពីភូមិ ១ ទៅភូមិ ១ ទៀត មិនទាន់បានជួប «ស្រីពិត» នៅឡើយ គឺជួបតែ «ញី» ។ ពេលមួយនោះ ធនញ្ជ័យធ្វើដំណើរដល់ផ្ទះនាងសួស្តីក្នុងភូមិមួយនោះ ។ ដោយចៃដន្យ ធនញ្ជ័យបានជួបនាងម្ចាស់ផ្ទះអង្គុយនៅមុខគេហដ្ឋាននាង, ធនញ្ជ័យក៏ដណ្តឹងសួរនាងថា ៖*

*«អ្នកប្អូននៅទីនេះ មានស្រីទេ ឯនាងសួស្តីស្តាប់ហើយ ឆ្លើយថា អ្នកឯងនេះ នៅស្រុកណាមានទេប្រុសក្នុងស្រុកអ្នកឯង, ឯធនញ្ជ័យស្តាប់ហើយ ក៏គិតថា នេះហើយគេហៅថា ស្រីសួស្តី ទើបធនញ្ជ័យប្រាប់ថា ឯស្រុកខ្ញុំមានប្រុសដែរ តើនាងដឹងឬទេឈ្មោះប្រុសនោះឯង នាងសួស្តីថា ខ្ញុំដឹងបានជាគេហៅប្រុសនោះដ្បិតគេឈ្មោះជ័យនោះឯង, ជ័យនោះច្រើនជាធំជាងអស់ឈ្មោះផង ជ័យឈ្នះអស់ក្នុងផែនដីនេះឯង បានជាហៅប្រុស ៗ នោះ ដ្បិតឈ្មោះជ័យនោះឯង ទើបនាងសួស្តីថា អ្នកឯងស្គាល់ទេស្រីនោះ ទើបធនញ្ជ័យថា ខ្ញុំស្គាល់បានជាគេហៅស្រី ៗ នោះ ដ្បិតតែឈ្មោះសួស្តីនោះឯងជាសួស្តីមង្គលជាធំ ក្នុងផែនដីនេះ នឹងរកឈ្មោះណាឲ្យដូចគ្មាន បានជាគេហៅស្រី ៗ នោះ ដ្បិតតែឈ្មោះសួស្តី ទើបធនញ្ជ័យសួរថា នាងមានខ្លាចឬគ្មានខ្លាចទេ នាងសួស្តីឆ្លើយថា ខ្ញុំគ្មានខ្លាចទេ ថា អ្នកឯង តើមានក្រែងឬមិនក្រែងទេ ធនញ្ជ័យឆ្លើយថា គ្មានក្រែងអ្វីទេ ហើយធនញ្ជ័យដណ្តឹងថា ខ្ញុំសួរនាងថា ខ្លាចឬគ្មានខ្លាចនោះ តើនាងដឹងឬទេ នាងសួស្តីឆ្លើយថា ខ្ញុំដឹងហើយ គឺអ្នកដណ្តឹងថា មានប្តីឬនៅឡើយ បើមានប្តីហើយខ្លាចប្តីដែរ បើគ្មានប្តីទេនោះ ថា មិនខ្លាចទេ ទើបនាងសួស្តីដណ្តឹងថា ក្រែងឬមិនក្រែងនោះ តើដូចម្តេចទើបធនញ្ជ័យប្រាប់ថា ខ្ញុំដឹងនាងឯងសួរខ្ញុំថា មានប្រពន្ធហើយឬនៅទេ បើមានប្រពន្ធហើយក្រែងចិត្តប្រពន្ធនោះ បើគ្មានប្រពន្ធទេ ថា មិនក្រែងចិត្តនរណាទេ ឯធនញ្ជ័យបានដឹងថា នាងសួស្តីគ្មានប្តី ដូច្នេះហើយក៏*

---

(៤៥) សួស្តី ឬ សួស្តី៍ មកពីពាក្យសំស្ក្រឹត « ស្វស្តិ » ៖ « មង្គល, សិរី... » ។

*ដាក់សំពាយអំពីស្មា ហើយស្រាយសំពាយហូលចេញឲ្យម្ដាយឪពុកនាងសួស្ដីឃើញ ។[(៤៦)]»*

*ដោយដឹងថា នាងសួស្ដីមិនទាន់មានប្ដី ក៏ចូលស្ដីដណ្ដឹងដល់មាតាបិតានាងសួស្ដីតាមប្រពៃណី ។ បន្ទាប់ពីធ្វើពិធីរៀបការសព្វគ្រប់ហើយ អ្នកទាំង ២ ត្រឡប់ចូលទីក្រុងវិញ ។*

*រឿងធនញ្ជ័យ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងរឿងល្បែង* **លោកនយ-បករណ៍**[(៤៧)] *ដែលមានតួអង្គឯកនាមធនញ្ជ័យ[(៤៨)] ដែរ ដូចមានសម្រង់សេចក្ដីសង្ខេបពី «ការស្វែងរកស្រីគ្រប់លក្ខណ៍» ដូចខាងក្រោមនេះ ៖*

*«នៅភូមិកប្បាសគ្រាម មានបុរសម្នាក់ នាម កុលកោសី និងភរិយា នាម នាងនាដនិធិនី ។ នាងនាដបានបុត្រីម្នាក់ ឈ្មោះ កល្យាណី ។ ពេញវ័យគម្រប់ជន្មាយុ ១៦ ឆ្នាំ នាងប្រកបដោយរូបឆោមលោមពណ៌ល្អឥតផ្ទឹម គឺជា "ស្រីគ្រប់លក្ខណ៍"» ៖*

«នាងនាដនិធិនី　　　　　　កបកើតកូនស្រី

---

(៤៦) ធនញ្ជ័យ, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨, ទំព័រ ៥០–៥១ ។ P. Bitard, *op. cit.*, p. 40 ។

(៤៧) លោកនយបករណ៍, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៥៨, ២ ភាគ ។ រឿងល្បែងនេះនិពន្ធឡើងជាកំណាព្យដោយ « នង » នៅឆ្នាំ ១៧៩៤ ។ សូមអាន Khing Hoc Dy, *op. cit.*, p. 25–27 ។

(៤៨) អ្នកស្រី É. Porée Maspero បានធ្វើសេចក្ដីសង្កេតលើកំណត់លោក Aymonier, (*Cambodge*, III, p. 321, n. 2) ដូច្នេះ ថា « Il mes paraît peu probable que le nom de Thméñ Cei, Dent de la Victoire soit "la corruption" du sanscrit Dhanañjaya, quoique les Cambodgiens aient certainement fait l'équation des deux noms d'Agni, le dieu du feu, ce qui est une indication de la façon dont les confusions se produisent (...). Cette note est relative à un passage de la grande inscription moderne d'Angkor Vat (1701 A.D.) où il est question d'une vie antérieure du Bouddha qui, sous le nom de Dhmeñ Jai, résolvait allègrement, en vertu de sa perfection suprême, des énigmes du Yakkha (ogre) Nandi, sauvant la vie du roi (son maître) en conduisant le Yakkha Nandi sous le figuier, et tremblant de crainte dans la suite du roi ... », *op. cit.*, p. 547, n° 3 et 4 ។ សូមអាន S. Pou, « Inscriptions modernes d'Angkor 34 et 38 », *BEFEO* (LXII), 1975, p. 322, n° 88 ។

| | |
|---|---|
| សន្មតនាមា | នាងកល្យាណី [៤៩] |
| បុត្រីពំងា | រូបរាងសោភា |
| សុភាពល្អល្អះ ។ | |
| បីដូចព្រះចន្ទ | ពេញបូណ៌មីស្បាន់ |
| រុងរឿងរីករះ | ពីបូព៌ទិសទី |
| រស្មីថ្លាជ្រះ | ចែងចាំងព្រោងព្រះ |
| ភក្ត្រជាត់ផូរផង់ ។ | |
| ហាក់ដូចស្រីសួគ៌ | គំនាប់គំនួរ |
| សក្តិសមអស់អង្គ | ទ្រទេសទ្រទន់ |
| ល្វាសល្វន់ត្រចង់ | ត្រចះវរវង្ស |
| វរវេសស្រៀវស្រស់ ។ | |
| ប៉ប្រិមប៉ប្រៃ | គាប់គួរល្មមល្មៃ |
| មិនទាបមិនខ្ពស់ | មិនធាត់មិនធំ |
| សោតសមកម្ពស់ | ជូនចូលសោឡស |
| វស្សាជៀងជាក់ ។ | |
| កបកើតបញ្ចពិធ | កល្យាណវរថៃ |
| ត្រឹមត្រូវ**ត្រូវលក្ខណ៍** | ល្អលើសលែងស្រី |
| ផែនដីភពចក្រ | ឯកឯងឥតអ្នក |
| ណានឹងផ្ទឹមផ្ទាល់ ។ [៥០] » | |

*នាងកល្យាណីមានប្រាជ្ញាប្រាជ្ញប្រុះឆ្លាសឆ្មុះ រមែងរៀបចំម្ហូបចំណីរាល់ថ្ងៃសម្រាប់បិតាទៅធ្វើចំការ ។ ថ្ងៃមួយ នាងបានយកបាយបង្អែមទៅជូនបិតា ក៏បានជួបធនញ្ជ័យកុមារតាមផ្លូវ ។ អ្នកទាំងពីរមានចាប់ចិត្តចាប់អារម្មណ៍គ្នាទៅវិញទៅមកហើយ ក៏ចោទប្រស្នាគ្នាទៅវិញទៅមក ៖*

| | |
|---|---|
| « នាងឆ្លើយថា | ម្ចាស់អើយខ្លួនខ្ញុំ |

---

(៤៩) **កល្យាណី** (បាលី) ៖ ស្រីដែលសម្រស់ល្អ ។

(៥០) *លោកគជយបករណ៍*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៥៨, ភាគ ២, ទំព័រ ២១៥ ។

មកមិនទើសទាល់ ទាស់ទែងទោសទុក្ខ
សាន្តសុខក្រសាល អង្គឥតពីភាល់
ភារភ័យសម្ងាយ ។
ឯអាថិប្រស្នា ចំណោទព្រះមហា
បុរសប្រាជ្ញប្រាយ ថែងចោទនារី
ស្រស់ស្រីឆោមឆាយ ជាហេតុឧបាយ
កលកិច្ចឡើងឡប់ឡាក់ ។
បើនាងថាមាន ភារភ័យព្រួយប្រាណ
ប្រាកដជៀងជាក់ នោះនាងមានប្ដី
ស្វាមីរូមរក្ស ក្រែងប្ដីអន់អាក់
ប្រចណ្ឌសង្ស័យ ។
បើនាងថាពុំ មានមោះអង្គអំ-
ពល់ពីភារភ័យ នោះនាងមិនមាន
ប្រុសប្រាណដទៃ ជួបចាប់ប្រស្រ័យ
ជាគូកាន់ក្ងួច ។
ពង្សពុទ្ធចមច័ក្រ ស្ដែងស្ដាប់ជៀងជាក់
ចូលចិត្តព្រឺព្រួច ព្រឺសព្រះហឫទ័យ
អរក្រៃលនលួច ក្រឡាប់កាន់ក្ងួច
ចួបចាប់ប្រតិព័ទ្ធ ។
ទើបយាងព្រះបាទ ទៅទៀបនាងនាដ
នារីរូបរ័តន៍ ប្របប្រាណបានបែរ
រួសរេដល់ជិត ថាមេមាសមិត្រ
នាមនាងឈ្មោះអ្វី ។
នាងស្ដាប់វាចា គន់គិតថៃថា
អ្នកនេះពីសី ល្អល្អះអស់អង្គ
ប្រុសក្នុងលោកិយ បិតឋានផែនដី
មិនមានជិតដល់ ។

បើល្អតែរាង　　　　រូបឆោមស្អាតស្អាង
អាប់ឥតយោបល់　　　　ល្ងង់ល្ងើកំឡៅ
ខ្លួនខ្លៅឆ្វាយឆ្ងល់　　　　គន់គិតពុំយល់
ការកិច្ចប្រស្នា ។
បើចិត្តចង់បាន　　　　អង្គអញមិនមាន
ចិត្តចាប់ចេតនា　　　　គិតគួរលលេង
ប្រាប់ល្បួងទៅជា　　　　កិច្ចកលប្រស្នា
ចង់ដឹងសេចក្តី ។
នាងនាដគន់គិត　　　　ស្រាប់ស្រេចស្រីរ័តន៍
ឆ្លាស់ឆ្លើយទៅខ្មី　　　　ថាអ្នកប្រុសអើយ
អ្នកអើយមានអ្វី　　　　ប្រសើរឯស្រី
នោះឯងឈ្មោះខ្ញុំ ។
ព្រះពង្សពុទ្ធរ័តន៍　　　　បញ្ញាបរមត្ថ
បារមីបរម　　　　សាស្តាស្តែងស្តាប់
សារសព្វកិច្ចកំ–　　　　ប៉ាំងបានដឹងជំ–
ណើរនោះជៀងជាក់ ។
ពិតពុំឆ្វាយឆ្ងល់　　　　នឹងព្រះយោបល់
ប្រាជ្ញប្រុះប្រត្យ័ក្ស　　　　មិនមានទើសទាល់
សេសសល់ជំពាក់　　　　ឥតឯថ្នាំងថ្នាក់
ក្នុងព្រះចិត្តា ។
ទើបអ្នកឆ្លើយទៅ　　　　ថាហៃប្អូនពៅ
ពាលពេញពំងា　　　　ឈ្មោះ**ភល្យាឈី**
ឬអ្វីប្អូនភ្ញា　　　　នាមនេះជាក់ជា
ប្រសើរឯស្រី ។
នាងឆ្លើយថាអើ　　　　ឯអម្ចាស់តើ
នាមហៅឈ្មោះអ្វី　　　　អ្នកឆ្លើយថាហៃ
មាសថ្លៃប្រឹមប្រិយ　　　　ចូរប្អូនពីសី

ស្តាប់បងចរចា ។
បងនឹងប្រាយប្រាប់ អ្វីមួយពុំគាប់
ព្រះទ័យក្សត្រា ជាឈ្មោះបងចូរ
ចូរពៅពុំងា មាសមានប្រាជ្ញា
ឯងអធ្យាស្រ័យ ។
នាងនាដនិមិល ប្រាជ្ញប្រតិពល
ជវ័នវាងវៃ យល់អាថ៌ជាក់ច្បាស់
គឺហៅឈ្មោះ**ជ័យ** ដ្បិត**ជ័យ**នោះនៃ
បន្លែថាឈ្នះ ។
ធម្មតាមហាក្សត្រ សោយរាជសម្បត្តិ
ព្រះទ័យមានះ ប្រកបរិទ្ធី
បារមីតេជះ ឮគេថាឈ្នះ
ពុំក្សាន្តចិន្តា ។ ... (៥១) »

*ក្រោយមក ធនញ្ជ័យនិងនាងកល្យាណី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតទៅ ។ សរុបសេចក្ដីមក ធនញ្ជ័យឬធ្មេញដៃ រឿងព្រេងប្រជាប្រិយ និងធនញ្ជ័យក្នុងរឿងល្បែងលោកនយបករណ៍ មានតួនាទីសំខាន់មួយដូចគ្នា គឺ «ការស្វែងរកស្រីពិត» ដែលជា «ស្រីគ្រប់លក្ខណ៍» ។ យើងសង្កេតឃើញ «ការស្វែងរកស្រីពិត» នេះ មាននៅក្នុងរឿងជាតកសំខាន់មួយទៀត គឺ* **មហោសថជាតក** *។ ព្រះមហោសថជាអ្នកប្រាជ្ញក្នុងនគរ ទៅ «ស្វែងរកស្រីពិត» ជា «ស្រីគ្រប់លក្ខណ៍» ធ្វើជាភរិយា ។ ព្រះមហោសថ និងនាងអមរា*(៥២) *សន្ទនាគ្នាទៅវិញទៅ ដោយប្រស្នា ហើយជាចុងក្រោយ ព្រះមហោសថក៏យល់ថា នាងអមរាជា «ស្រីគ្រប់លក្ខណ៍»*(៥៣) *។*

---

(៥១) *លោកនយបករណ៍*, ... ភាគ ១, ទំព័រ ២១៧–២១៨ ។

(៥២) *អមរា* មកពីពាក្យសំស្ក្រឹត « អមរៈ » ៖ មិនចេះស្លាប់, អមតៈ ... ។

(៥៣) សូមអានសាស្ត្រាមហោសថ, មាន ១៥ ខ្សែ, តម្កល់នៅបណ្ណាល័យជាតិក្រុងប៉ារីស ចុះលេខ Indochinois 368 /camb. 88/ ។ ឈឹម–ស៊ុម, *សង្ខេបទសជាតក៍*, ភ្នំពេញ, ១៩៦១, ទំព័រ ១០៨–១៩០ ។

ប្រសិនបើយើងសិក្សាប្រៀបធៀបរឿងទាំង ៣ នេះ យើងឃើញថា រឿងព្រះមហោសថ មានចំណាស់ជាងគេ ព្រោះជារឿងជាតក ដែលមានក្នុងព្រះគម្ពីរព្រះត្រៃបិដក ក្នុងព្រះសូត្រ ។ ហេតុនេះ អាចទាញជាយោបល់ថា រឿងជាតកជាប្រភព ហើយមានឥទ្ធិពលខ្លាំងក្លាទៅលើអក្សរសិល្ប៍ខ្មែរយើងទូទៅ ជាពិសេសនៅរវាងសតវត្សទី ១៨ - ទី ១៩ ដែលជាផលិតកម្មកម្លាយចេញពីឥទ្ធិពលពុទ្ធសាសនា ។

ជាបញ្ចប់ យើងសូមបញ្ជាក់ថា ការសិក្សានេះគ្រាន់តែជាការបង្ហាញត្រួស ៗ លើប្រធានបទមួយក្នុងអក្សរសិល្ប៍ប្រជាប្រិយខ្មែរតែប៉ុណ្ណោះ ទុកឲ្យអ្នកសិក្សាស្រាវជ្រាវឯទៀតបន្តការសិក្សាបន្តទៅទៀត ។ ក្នុងទស្សនៈខ្មែរយើងជាប្រពៃណីរមែងយល់ថា ជីវភាពសុខសុភមង្គលសិរីសួស្តីនានា អាស្រ័យទៅលើលក្ខណៈស្ត្រី គឺអាច « យោង » បុរសឲ្យបានរួចពីទុក្ខសោក ទៅកាន់សេចក្តីសុខចម្រើនបាន ដូចពាក្យទំនៀម ដែលពោលមកហើយថា គឺ « សំណាបយោងដី ស្រីយោងប្រុស » ។ ស្រីពិតមានលក្ខណសម្បត្តិទាំងផ្លូវចិត្ត ហើយលក្ខណៈនេះមានលេចចេញនៅលើរូបរាងកាយទៀតផង ។

លក្ខណៈសម្គាល់លើខ្លួនប្រាណរូបកាយនោះ មាននៅលើបុរសនិងនៅស្ត្រី ។ ក្នុងអាស៊ីអាគ្នេយ៍ ដែលទទួលឥទ្ធិពលពីឥណ្ឌា, ប្រពៃណីប្រជាប្រិយបានរក្សាចំណេះដឹងពីលក្ខណៈ ដែលមានលើរូបកាយ(៥៤) ដូចមានឃើញនៅលើក្បួនទស្សន៍ទាយនានា, ក្បួនសិល្ប៍មន្តអាគមគាថារបៀនយ័ន្ត(៥៥) ជាដើម ដែលទាក់ទងនឹងលក្ខណៈជាប់នឹងខ្លួនប្រាណ ដូចមានបញ្ជាក់ក្នុងរឿងព្រេង, រឿងល្បែងនានា ។ បានសេចក្តីថា យើងមានជំនឿថា ប្រសិនបើ

---

(៥៤) Cf. S. Bernard-Thierry, « Note sur les signes corporels dans l’Inde ancienne », *Bulletin de la Société d’Anthropologie*, t. 5, 1954, p. 247 ។

(៥៥) នួន-ប៊ុត, *ព្យាករណសាស្រ្ត*, ភ្នំពេញ, ១៩៦៦, ៩២ ទំព័រ (សូមអាន « លក្ខណៈម្រាមដៃ, លក្ខណៈប្រជ្រុយ របស់ស្ត្រី », ទំព័រ ៣៥–៤៥) ។ អាចារ្យ ឈូក–និបផាន់, *វិជ្ជាវេទមន្តគាថាការពារខ្លួន*, ភ្នំពេញ, ១៩៧១, ២១០ ទំព័រ ។ កង–ផាន់, *ក្បួនវេទមន្តព្រមទាំងសីលវិជ្ជា–អាគម–គាថា–យ័ន្ត*, ភ្នំពេញ, ១៩៧១, ១៥៣ ទំព័រ ។

បុរសស្ត្រីណាមានលក្ខណៈជាប់នឹងរូបកាយ អាចនាំមកនូវសេចក្តីសុខចម្រើនមានបាន ។ ជួនកាល លក្ខណៈលើរូបកាយនេះ ប្រឌិតឡើង ដោយសាក់លើខ្លួនប្រាណផ្ទាល់ ជាយ័ន្តនានា ដើម្បីឲ្យបានខ្លាំងពូកែឈ្នះមារសត្រូវ[៥៦] ៕

(៥៦) M. Bouteiller, « Le tatouage : technique et valeur sociale ou magico-religieuse, dans quelques sociétés d’Indochine (Laos, Siam, Birmanie et Cambodge) », *Bulletin de la Société d’Anthropologie,* t. 4, 1953, p. 515-534 ។